ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ

* ចំណុចចម្លែកពាក់ព័ន្ធការបង្រួមបង្រួមសាលានៅទីជ្រាំងនៅមក
* ការកសាងនិងការលើកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្រូបង្រៀនទាំងផ្លូវចិត្ត - សម្ភារៈ

៣៦

# ទស្សនាវដ្តី គ្រូបង្រៀន



ផ្ទះគ្រូបង្រៀន ខេត្ត រតនគីរី

ខែ កក្កដា-សីហា-កញ្ញា ឆ្នាំ ២០០៨

# មាតិកា

### គណៈកម្មការរៀបរៀង និងនិពន្ធ

- លោកស្រី ប៊ុន សារ៉ន
- លោកស្រី ហួរ ស៊ីវ
- លោកស្រី ប៉ែន ណាវុល
- លោក ថោង បូរ៉ាន់
- លោក ស្រី គុយ ផល្លា
- លោកស្រី ប្រាក់ សូលីដា
- លោក ជន ឈាងលី
- លោក កៅ ជឿន
- លោក ស្វាយ ទិត្យ
- លោក ដុំ ហ៊ីន
- លោក ប៉ែន សារុន
- សមាជិក_សមាជិកាស.ប.ស.ខ

### គណៈកម្មការត្រួតពិនិត្យ

- លោក យស់ អ៊ាង
- លោក សួង សារុណ
- លោក ស៊ុង វ៉ាន់ថន
- លោកបណ្ឌិត អ៊ុំ កុច
- លោក ស៊ិន ស៊ីម
- លោក អ៊ិន ថេវ
- លោកស្រី ទន់ សាអ៊ុម

### វិចិត្រករ

លោក ចាន់ ត្រា

### ការីកុំព្យូទ័រ

កញ្ញា ម៉ៃ សុនី

### គ្របខាងក្រៅ

- ពីមុខ: ផ្ទះគ្រូបង្រៀនខេត្តតាកែវ
- ពីក្រោយ: ព្រះករុណាស៊ីសុវត្ថិយាងទៅប្រទេសបារាំង


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| | **វប្បធម៌ទូទៅ** | |
| ២ | ប្រពៃណីប្រើប្រាស់ទៀនក្នុងសង្គមខ្មែរ | ២ |
| ៣ | ការជួយមាតាបិតាក្នុងការអប់រំបុត្រធីតា | ៥ |
| ៤ | ជីវិត និងសេចក្ដីស្លាប់ | ៧ |
| | **ចិត្តវិទ្យា-អប់រំ** | |
| ៥ | យល់ដឹងអំពីទារកភាព | ៩ |
| ៦ | ដំណាក់រងទាំង៦ នៃដំណាក់ឥន្ទ្រីយ៍ចលកររបស់លោកព្យាហ្សែត៍ | ១២ |
| | **វិទ្យាសាស្ត្រ និងព័ត៌មានវិទ្យា** | |
| ៧ | តារារណបសម្រាប់អ្នកគូរផែនទី | ១៥ |
| | **ការអប់រំ និងគរុកោសល្យ** | |
| ៨ | ទំនាញសួរ | ១៧ |
| ៩ | មូលភេទ អ-អិ (ត) | ១៩ |
| ១០ | ភាសា : កុំច្រឡំ | ២១ |
| ១១ | គណិតវិទ្យា : ការដោះស្រាយចំណោទ (ត) | ២៣ |
| ១២ | គណិតវិទ្យា : ចំណោទ | ២៥ |
| ១៣ | គំនូរ : វិធីបង្រៀនគំនូរ (ត) | ២៦ |
| | **នាទីកំណាព្យ និង កំសាន្ត** | |
| ១៤ | ប្រទេសកម្ពុជាពី គ.ស.១៨៤០ (ត) | ២៩ |
| ១៥ | រណសិរ្សពីរធ្នូ | ៣២ |
| | **វេទិកាស្ត្រី** | |
| ១៦ | ល្បែងបំពេញលេខស៊ូដូគុ | ៣៤ |
| ១៧ | វេទិកាស្ត្រី : ការយល់ដឹងអំពីអនុសញ្ញាសហប្រជាជាតិស្ដីពី...(ត) | ៣៨ |
| | **ព័ត៌មាន** | |
| ១៨ | តើលោកគ្រូ អ្នកគ្រូ ដឹងទេថា... | ៤១ |
| ១៩ | រដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍ | ៤២ |
| ២០ | តារាងស្ថិតិសាលារៀន ថ្នាក់រៀន សិស្ស និងបុគ្គលិកឆ្នាំ២០០៧-០៨... | ៤៤ |
| ២១ | ស្ថិតិសពខែមេសា-ឧសភា-មិថុនា ឆ្នាំ២០០៨ | ៤៧ |



**ទូរស័ព្ទផ្ទះគ្រូបង្រៀន**

ភ្នំពេញ : ០១២ ៨៩៧ ១៧៧, កំពត : ០១២ ៨៥៦ ៧២២, ក្រុងព្រះសីហនុ : ០១២ ៦៥៩ ៥៦០

សៀមរាប : ០១២ ៦៧៥ ៦៤០ តាកែវ : ០១២ ១ ៧០៣ ០៧៧ កំពង់ចាម : ០១១ ៧៤២ ២២៤

# វិចារណកថា

ពាក្យទំនៀមខ្មែរពោលថា "ចោកអ្វីនឹងដៃ ថ្លៃអ្វីនឹងមាត់"។ ប្រយោគនេះបង្ហាញពីគុណតម្លៃនៃសង្គមខ្មែរក្នុងការប្រាស្រ័យទាក់ទងគ្នា ដូចជាកាយវិការជម្រាបសួរ ជម្រាបលា សុំទោស អរគុណ ការអោនលំទោន ការលើកដៃសំពះ ការញញឹមរកគ្នា ការយល់អធ្យាស្រ័យគ្នា... ដែលទង្វើទាំងអស់នេះមានលក្ខណៈល្អប្រពៃ និងបង្ហាញអំពីជីវភាពស្មារតី សម្ភារៈ និងវប្បធម៌របស់ជាតិខ្មែរ។

សម្រាប់ប្រជាជនខ្មែរ មិនថាចាស់-ក្មេង ប្រុស-ស្រី ការធ្វើវត្តប្រតិបត្តិ បានក្លាយជាទម្លាប់ដែលប្រជារាស្ត្រថ្វាយបង្គំព្រះមហាក្សត្រ ពុទ្ធមាមកៈថ្វាយបង្គំព្រះសង្ឃ កូនសំពះ-ថ្វាយបង្គំឪពុកម្ដាយ សិស្សសំពះគ្រូ ក្មេងសំពះចាស់... ក្នុងទឹកចិត្តគោរព ស្រឡាញ់ និងដឹងគុណ... ខណៈពេលដែលពាក្យសំដីនិយាយប្រាស្រ័យទាក់ទងគ្នា ក៏ពោរពេញដោយការរាក់ទាក់ស្និទ្ធស្នាល គួរសម ដឹងខ្ពស់ទាប...។

ប៉ុន្តែជាអកុសល វិបល្លាសនយោបាយក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ បានរុញច្រានប្រទេសជាតិឱ្យធ្លាក់ក្នុងសង្គ្រាមបង្ហូរឈាម បំផ្លិចបំផ្លាញដល់គ្រប់កោសិកាសង្គម និងបានបន្សល់នូវផលវិបាកធ្ងន់ធ្ងររហូតមកពិសេសផ្នែកសីលធម៌ (ការប្រព្រឹត្តតែអំពើល្អ ដោយកាយ វាចា និងចិត្ត) ក្នុងការប្រាស្រ័យទាក់ទងគ្នា។

បន្ទាប់ពីទិវាជ័យជម្នះ ៧ មករា ១៩៧៩ គណបក្សប្រជាជនកម្ពុជាបានដឹកនាំស្ដារ និងកសាងប្រទេសដោយចាប់ផ្ដើមពីគ្មានអ្វីទាំងអស់ រហូតបានក្លាយជារដ្ឋមួយមានគ្រប់លក្ខណៈសម្បត្តិ ដូចបណ្ដាប្រទេសក្នុងតំបន់ និងពិភពលោក។ សម្រាប់កម្ពុជា អ្វីដែលជាចំណោទនៅឡើយ និងត្រូវបន្តយកចិត្តទុកដាក់ គឺការលើកកម្ពស់តម្លៃសីលធម៌ឡើងវិញ ដោយយោងដល់ការសិក្សាអប់រំ តាមរយៈសាលារៀន និងការទូន្មានប្រៀនប្រដៅ តាមរយៈគ្រួសារ និងសង្គមអំពីសុជីវធម៌ទាក់ទងនឹងរបៀបរៀបរយ សណ្ដាប់ធ្នាប់ អធ្យាស្រ័យ ក៏ដូចជាការគួរសម ការដឹងប្រមាណក្នុងការប្រាស្រ័យទាក់ទងគ្នា...។

ក្នុងដំណើរវិវត្តរបស់ខ្លួន សង្គមឈានទៅមុខជានិច្ច និងទាមទារឱ្យការរស់នៅកាន់តែចុះសម្រុងគ្នាជាសុខឥតមោះហ្មង ទាំងការប្រកបការងារ ទាំងការប្រើប្រាស់សិទ្ធិ និងសេរីភាព ទាំងការបំពេញភារកិច្ច និងកាតព្វកិច្ច... ពិសេសការប្រាស្រ័យទាក់ទងគ្នា។ ជាក់ស្ដែង មនុស្សចាំបាច់ត្រូវតែមានទំនាក់ទំនង ហើយត្រូវតែជាទំនាក់ទំនងល្អ។

ដើម្បីសម្រេចគោលដៅនេះ គ្រួសារ សាលារៀន និងសង្គម មានភារកិច្ចរួមគ្នា អប់រំ បណ្ដុះបណ្ដាល ទូន្មាន និងធ្វើជាគំរូក្នុងការប្រតិបត្តិសីលធម៌ សុជីវធម៌សម្រាប់ជំនាន់មនុស្សថ្ងៃនេះ ដើម្បីថ្ងៃស្អែក សង្គមកម្ពុជាក្លាយជាសង្គមថ្កើងរុងរឿងខ្ពស់ត្រដែត។

**គណៈកម្មាធិការនាយក**




## ប្រពៃណីប្រើប្រាស់ទៀនក្នុងសង្គមខ្មែរ

នៅបណ្ដាប្រទេសជាច្រើនក្នុងទ្វីបអាស៊ី ពិសេសប្រទេសដែលប្រកាន់តាមជំនឿព្រះពុទ្ធសាសនា គេនិយមប្រើប្រាស់ទៀន ដើម្បីរៀបចំជាទេយ្យវត្ថុ ឬវត្ថុជាទីសក្ការៈផ្សេងៗ។ ចំពោះប្រទេសកម្ពុជាវិញ ទៀនត្រូវបានគេចាត់ទុកជាគ្រឿងសក្ការៈបូជាមួយយ៉ាងសំខាន់ក្នុងចំណោមគ្រឿងសក្ការៈផ្សេងៗទៀត។ ចំពោះទៀនណាដែលគេយកមកប្រើប្រាស់ក្នុងពិធីនានា ទោះក្នុងផ្នែកសាសនាក្ដី ផ្នែកទំនៀមទម្លាប់ក្ដី ផ្នែកជំនឿផ្សេងៗក្ដី គេហៅថា ទៀននិមិត្ត។

ក្នុងការសិក្សាស្រាវជ្រាវពីដើមកំណើតនៃទៀន យើងពុំបានដឹងប្រាកដទេថា ទៀនមានដើមកំណើតពីពេលណាទេ តែបើតាមចាស់បុរាណបាននិទានតៗគ្នាមកថា ទៀនមានដើមកំណើតតាំងពីសម័យព្រះពុទ្ធអង្គគង់ព្រះជន្មនៅឡើយ។ តាមរឿងព្រេងនិទានតំណាលថា កាលណោះមានព្រះរាជាមួយអង្គព្រះនាមព្រះបាទស័ង្ខចក្រ។ ព្រះអង្គមានព្រះបរមរាជនាមថា ព្រះបាទសម្ដេចព្រះស័ង្ខចក្រព័ត្ររាជាធិរាជ សោយរាជ្យនៅមហានគរសម័យ។ ថ្ងៃមួយ ព្រះរាជាទ្រង់ព្រះសណ្ដាប់ការសម្ដែងធម្មទេសនារបស់ព្រះសម្មាសម្ពុទ្ធ។ អាស្រ័យដោយខ្លឹមសារនៃធម្មទេសនាមានអត្ថន័យពិរោះអស្ចារ្យពេកក្រៃ បណ្ដាលឱ្យព្រះរាជាមានព្រះទ័យជ្រះថ្លាពន់ប្រមាណក្នុងការបូជាចំពោះព្រះធម៌។ ព្រះរាជាទ្រង់ត្រាស់បង្គាប់ឱ្យអាមាត្យយកកំណាត់សំពត់ជ្រលក់ប្រេងរុំព្រះកាយព្រះអង្គចាប់តាំងពីព្រះបាទរហូតដល់ព្រះសិរសា។ នៅលើព្រះសិរសាមានចងរូបរាងជាប្រឆេះ រួចអុជឱ្យឆេះបូជាថ្វាយព្រះធម្មទេសនានៅគ្រានោះទៅ។ តែពេលនោះមានកើតហេតុការណ៍ដ៏អស្ចារ្យ បណ្ដាលមកពីបុណ្យបារមីនៃទឹកព្រះទ័យដែលជ្រះថ្លានោះ ភ្លើងពុំមានឆាបឆេះព្រះកាយព្រះរាជាសោះឡើយ ដោយភ្លើងនោះប្រៀបបាននឹងទឹកត្រជាក់ទៅវិញ។

ខ្លឹមសារនៃបុរាណនិទាននេះ សមហេតុផលម្យ៉ាងដែរ ព្រោះរូបរាងទៀន ប្រហែលនឹងរូបមនុស្សឈរពិតប្រាកដ។ តាមការកត់សម្គាល់ជាទូទៅ នៅប្រទេសកម្ពុជាយើង ទៀនមានរូបរាង ឈ្មោះ និងរបៀបប្រើប្រាស់ប្លែកៗពីគ្នាទៅតាមតំបន់។

**១-ទៀនកល្ប**

ទៀនមួយប្រភេទធំ ខ្លី សម្រាប់អុជជូនដំណើរបុគ្គលដែលជិតនឹងទទួលមរណភាព។ កាលពីបុរាណ ទៀននេះគេធ្វើពីក្រមួនសុទ្ធ មានទំហំប៉ុនមេជើងបុគ្គលដែលស្លាប់ ទម្ងន់មួយតម្លឹងក្រមួនសុទ្ធ ប្រនេះធ្វើពីអំបោះនៅមានចំនួន ១៩សរសៃ ឬ៣២សរសៃ។ នៅពេលមនុស្សហៀបផុតដង្ហើម គេដុតទៀនកល្បនៅពីលើក្បាលដំណេកបុគ្គលដែលស្លាប់ អមដោយប្រអប់ស្លា ម្លូ និងពែងទឹក។ ទៀននេះជានិមិត្តរូបនៃសង្ខារមនុស្សដែលនឹងងាយរលត់ ដូចជាអណ្តាតភ្លើងទៀន។ ចាស់ៗពីបុរាណចាត់ទុកថា មនុស្សដែលស្លាប់ភ្លាមៗមិនទាន់ចែកឋានទៅណាទេ តែគេសន្មតទៅតាមលក្ខណៈទៀន២ប្រភេទ គឺការអុជទៀនគោល និងទៀនកល្ប។ បើអុជទៅហើយៗទៀននេះឆេះអស់ តែពុំឃើញមនុស្សរស់ឡើងវិញ ទើបគេចាត់ទុកថា មនុស្សស្លាប់នេះចែកឋានពិតប្រាកដ។

## ២_ទៀនគោល

ទៀនធំធ្វើពីក្រមួនសុទ្ធ ទម្ងន់តាំងពី១តម្លឹងឡើងទៅ សម្រាប់ប្រើក្នុងពិធីបុណ្យ និងពិធីមង្គលការផ្សេងៗ ឬបិទនៅគ្រែទេសនាដោយសន្មតថា ជាគោលលើអស់ទៀនទាំងពួង។ ទៀននេះមានមុខងារ និងអត្ថន័យទូលំទូលាយ។ គេប្រារព្ធប្រើក្នុងពិធីច្រើនប្រភេទ ក្នុងពិធីសាសនា ក្នុងពិធីទំនៀមទម្លាប់ដូចជាសំណាក់ធមិព្រះកម្មដ្ឋាន បំបួសនាគ បញ្ចុះសីមា ពុទ្ធាភិសេក អាពាហ៍ពិពាហ៍ ពិធីបុណ្យខ្មោច ។ល។

បើប្រើសម្រាប់សំណាក់ធម្មព្រះកម្មដ្ឋាន គេត្រូវរៀបចំរកទៀនគោល៥ ទៀន១ទម្ងន់១តម្លឹង សាច់ក្រមួនសុទ្ធ ប្រនេះចំនួន១២សរសៃអំបោះនៅ ប្រវែងប្រមាណ១២ថ្នាប់មេដៃ។ រូបទៀនតំណាងរូបកាយ ប្រនេះតំណាងវិញ្ញាណ។ ទៀនគោលទាំង៥គេមិនដុតទេ តែគេរៀបតម្កល់លើក្បាលដំណេកជាមួយនឹងធូប៥សរសៃ ផ្កា៥ទង លាច៥កន្ទោង ស្លាធមិ១គូ ទឹកអប់២ដប ស្លា៥ បារី៥ដើម។ ទៀននេះគឺមានគ្រឿងណមហាមមិនឱ្យដើរកន្លងឡើយ។

ក្នុងពិធីបំបួសនាគ គេប្រើទៀនគោលសម្រាប់អ្នកបួស មិនមានខ្នាតច្បាស់លាស់ ទំហំ និងទម្ងន់ក៏គ្មានកំណត់។ ប៉ុន្តែប្រវែងត្រឹម២ចំអាម ទំហំមិនឱ្យតូចពេក ឬធំពេក។ ចាស់បុរាណធ្វើទៀនគោលសម្រាប់អ្នកបួស គេដាក់សរសៃប្រនេះទៅតាមរាសីអ្នកបួស។ តែក្នុងពិធីនេះ គេនិយមប្រើទៀនគោលតែ១ដើមទេ។

ក្នុងពិធីមង្គលការ គេប្រារព្ធប្រើទៀនគោលចំនួន២ គឺមួយតំណាងសាមីខ្លួនប្រុស និងមួយទៀតតំណាងសាមីខ្លួនស្រី។

ក្នុងពិធីបញ្ចុះសីមា ឬពុទ្ធាភិសេក គេនិយមប្រើទៀនគោលចំនួន ៨ ជាតំណាងឱ្យទិសទាំង៨។

ក្នុងពិធីបុណ្យខ្មោច ទៀនគោល១ ទម្ងន់១តម្លឹង កម្ពស់១២ថ្នាប់ ប្រនេះចំនួន១៩ ឬ៣២សរសៃ។ ចំនួន១៩ជានិមិត្តរូបនៃដួងព្រលឹងសម្រាប់ទ្រទ្រង់ជីវិត ឯចំនួន៣២ជានិមិត្តរូបនៃអាការទាំង៣២របស់មនុស្ស។ នៅពេលមនុស្សឈឺធ្ងន់ គេបម្រុងទៀនគោលទៅតាមលទ្ធភាពគ្រួសារ។ សម្រាប់អ្នកក្រចំនួន២ដើម គ្រួសារមធ្យមចំនួន៤ដើម គ្រួសារអ្នកមានចំនួន៨ដើម។ ពេលបុគ្គលផុតដង្ហើមភ្លាម អាចារ្យអ្នកនាំផ្លូវចាប់អុជទៀនគោលនេះ។

## ៣_ទៀនជ័យ

ទៀនធំសិតដោយក្រមួនចាប់ពីទម្ងន់ ១៦ នាឡិ ឡើងទៅ សម្រាប់អុជក្នុងពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ ឬអុជរៀបចំពិធីផ្សេងៗក្នុងព្រះបរមរាជវាំង។

ទៀនជ័យគេនិយមប្រើក្នុងពិធីអភិសេកឡើងសោយរាជ្យ បុណ្យខួបកំណើតព្រះរាជាជាដើម។ ទៀននេះធ្វើពីក្រមួនសុទ្ធទំហំប្រវែង២ហត្ថ និង២ធ្នាប់។ សរសៃប្រឆេះត្រូវយកទៅតាមចំនួនរាសីនៃព្រះរាជាអង្គនោះ ដែលមានកំណត់ព្រះជន្មវស្សាត្រូវឡើងគ្រងរាជ្យ ហើយត្រូវធ្វើមង្គល។ ទៀនប្រភេទនេះជានិមិត្តរូបនៃឫទ្ធិអំណាច និងជោគជ័យ។ គេនិយមអុជទៀននេះចំនួន៣យប់ ៣ថ្ងៃ ស្របទៅតាមចំនួនថ្ងៃធ្វើពិធីបុណ្យ។

### ៤-ទៀនវស្សា

ទៀនធំស្រដៀងគ្នានឹងទៀនជ័យ ប៉ុន្តែសិតដោយក្រមួនច្រើនតាមបាន ដែលទាយក ទាយិកា ធ្វើប្រគេនព្រះភិក្ខុសង្ឃក្នុងថ្ងៃ១៥កើត ឬថ្ងៃ១រោច ខែអាសាឍ សម្រាប់ព្រះភិក្ខុសង្ឃអុជបូជាព្រះរតនត្រ័យរាល់យប់ក្នុងរដូវចូលព្រះវស្សា។ ជាការកត់សម្គាល់ ទៀននេះគេមិនបានយកមកប្រើប្រាស់ច្របូកច្របល់ក្នុងពិធីបុណ្យផ្សេងៗ ដូចទៀននិមិត្តឯទៀតឡើយ។ ប៉ុន្តែគេប្រើប្រាស់ទៅតាមពេលវេលាកំណត់ក្នុងពុទ្ធបញ្ញត្តិ ពោលគឺក្នុងពិធីបុណ្យចូលព្រះវស្សារហូតដល់ពេលចេញព្រះវស្សាតែប៉ុណ្ណោះ។

### ៥-ទៀនបង្វិលពពិល

ពពិល (ន) ប្រដាប់ធ្វើដោយលោហជាតិ មានសណ្ឋានស្រដៀងគ្នានឹងស្លឹកពោធិ៍ សម្រាប់បិទទៀនអុជកាន់ហុចបន្តគ្នា បង្វិលបក់ផ្សែងចូលជុំវិញមនុស្ស ឬរបស់អ្វីដើម្បីឱ្យកើតស្រីសួស្ដី (វចនានុក្រមខ្មែរទំព័រ៧៣២)។

ដើម្បីធ្វើទៀននេះគេយកក្រមួនសុទ្ធ១តម្លឹងមកបែងចែកជា៣ លុញជាទៀនចំនួន៣ ប្រវែង១២ធ្នាប់ ដាក់ប្រឆេះចំនួន១២សរសៃ។

ពេលប្រើប្រាស់ក្នុងពិធីមង្គលការ ឬពុទ្ធាភិសេក អាចារ្យត្រូវយកទៀន១មកបត់ជា២ ដាក់ប្រឆេះទន្ទឹមគ្នា ហើយបិទភ្ជាប់នឹងពពិល។ ពពិលត្រូវមាន៣ស្របនឹងចំនួនទៀន។ ទៀនពពិលទាំង៣តំណាងឱ្យ ព្រះនារាយណ៍ ព្រះធរណី និងព្រះពិស្ណុការ។

### ៦-ទៀនស្នែងក្របី

ទៀននេះគេកំណត់ឈ្មោះវាស្របទៅតាមលំនាំរូបរាងដូចស្នែងក្របី។ គេធ្វើទៀននេះដោយផ្គុំទៀនរាយ២ជាមួយគ្នា។ គេយកទៀន១ពត់ជារង្វង់ស្នែងក្របី រួចបិទភ្ជាប់នឹងទៀន១ទៀតដោតនៅចំកណ្ដាលអង្ករមួយចានធំ មានប្រាក់កាក់៤ ដាក់លើអង្ករ។ ទៀននេះគេមិនអុជទេ គ្រាន់តែធ្វើឡើងសម្រាប់បូជា នឹកគុណគ្រូបាធ្យាយ ឬខ្មោចអារក្សអ្នកតាប៉ុណ្ណោះ។

ក្នុងពិធីមង្គលការតាមតំបន់ខ្លះ គេយកទៀនស្នែងក្របីទៅរៀបឱ្យពួកអ្នកលេងភ្លេងហៅថា "ព្រះពិស្ណុការ"។

នៅខេត្តកំពង់ស្ពឺ ភូមិត្រពាំងស្លា នៅពេលល្បៀងអារក្សម្តងៗ គេដាក់កន្ត្រាំងដែលមានទៀនស្នែងក្របីពីមុខដោយគេសន្មតថា កន្ត្រាំងនេះជាទីស្នាក់នៅរបស់អារក្ស។ កាលណា "រូប" យកទៀនស្នែងក្របីនេះមកដាក់នៅពីលើក្បាល គេសន្មតថា អារក្សចូលសណ្ឋិតក្នុងរូបហើយ។ (នៅមានត)

លោក ចាប សំណាង (ចូលនិវត្តន៍)
មន្ត្រីអប់រំសាលាគរុ.ខេត្តបាត់ដំបង

# ការជួយមាតាបិតាក្នុងការអប់រំបុត្រធីតា

ក្នុងបញ្ហាអប់រំ គេតែងទុកគ្រួសារនីមួយៗជាសាលារៀន មាតាបិតាជាគ្រូដើមរបស់មនុស្សគ្រប់រូប។ តាមគោលច្បាប់នៃការអប់រំថ្មី សាលារៀនមានភារៈជួយមាតាបិតាសិស្សឱ្យចេះជាបឋមនូវច្បាប់ និងរបៀបដឹកនាំកូនឱ្យបានជាពលរដ្ឋល្អ។ ដូច្នេះ គប្បីលោកគ្រូ អ្នកគ្រូទាំងឡាយឆ្លៀតរកឱកាស និងរិះរកមធ្យោបាយជួយបំភ្លឺមាតាបិតាសិស្ស ឱ្យយល់នូវវិធីអប់រំណាដែលប្រសើរៗសម្រាប់សាងអនាគតបុត្រធីតារបស់លោកទាំងនោះ។ តើវិធីអប់រំប្រសើរមានតម្លៃ យ៉ាងណា? ដើម្បីនឹងថ្លឹងនូវតម្លៃនៃការអប់រំ គប្បីលោកអ្នកព្រាងសំណួរមួយចំនួនដូចតទៅនេះ :

ចំពោះលោកអ្នកជាមាតាបិតា តើទ្រព្យអ្វីដែលមានសារៈសំខាន់ជាងគេ? យើងជឿជាក់ថា ទ្រព្យសម្បត្តិដែលអស់លោកអ្នកស្រឡាញ់ស្មើដោយជីវិតនោះ គឺច្បាស់ជាបុត្រធីតារបស់លោកអ្នក ហើយអស់លោកអ្នកនឹងមានជំនឿជឿជាក់ទៀតថា ការអប់រំមានអានុភាពអាចនឹងធ្វើឱ្យមនុស្សមានវាសនាល្អ ឬអាក្រក់បាន។ ន័យមួយវិញទៀតថា បើលោកអ្នកអប់រំកូនលោកអ្នកត្រូវជ្រើសរើសផ្លូវល្អ អនាគតបុត្រធីតារបស់លោកអ្នកនឹងមានរស្មីត្រចះត្រចង់ពុំខាន។ ទាមការសង្កេតរបស់យើង គំនិតអប់រំក្នុងលោកនេះ អាចនឹងបែងចែកជា ២ បែបបាន គឺ ÷

១- អប់រំដោយវិធីធម៌ក្ដៅ

២- អប់រំដោយវិធីធម៌ត្រជាក់។

ចាប់តាំងពីចុងសតវត្សរ៍ទី១៩ មក គេឃើញមានអ្នកប្រាជ្ញខាងគរុកោសល្យជាច្រើននាក់បានទទួលស្គាល់ថា "ការអប់រំតាមវិធីត្រជាក់បានសម្រេចលទ្ធផលល្អ មានអានុភាពប្រសើរជាងការអប់រំតាមវិធីធម៌ក្ដៅ"។ ប្រការនេះសមទៅតាមគោលគំនិតនៃព្រះពុទ្ធសាសនាដែលបានចែងទុកជាងពីរពាន់ឆ្នាំមកហើយ។

ចុះអប់រំតាមវិធីធម៌ត្រជាក់បានន័យដូចម្ដេច? អប់រំដោយវិធីធម៌ត្រជាក់ គឺអប់រំដោយវិធីល្អសមតាមបុរាណភាសិតលោកចែងថា "ល្អពុម្ព ល្អព្រះ"។ ត្រង់នេះបានន័យថា បើអស់លោកអ្នកចង់ឱ្យបុត្រធីតារបស់លោកអ្នកទៅជាមនុស្សចិត្តល្អ លោកអ្នកត្រូវប្រើវិធីចិត្តល្អ។ ចុះវិធីចិត្តល្អមានន័យដូចម្ដេចទៅទៀត? សូមជម្រាបជូននូវគោលគំនិតខ្លះដែលមានត្រាទុកក្នុងក្បួនខ្នាត គួរជូនដល់លោកអ្នកជាព័ត៌មានដូចតទៅនេះ :

១- វាចាដែលអស់លោកអ្នកថ្លែងទៅកាន់បុត្រធីតា គប្បីឱ្យមានការញញឹមជាមួយផង។

២- គប្បីលោកអ្នកឆ្លើយដោយស្និទ្ធស្នាលចំពោះសំណួរបុត្រធីតារបស់លោកអ្នក។

៣- គប្បីបម្រុងវត្ថុផ្សេងៗឱ្យដល់បុត្រធីតារបស់អស់លោកអ្នក នៅពេលបុណ្យទានផ្សេងៗ មានបុណ្យថ្ងៃកំណើតជាដើម។

៤- ទទួលបុត្រធីតារបស់អស់លោកអ្នកដោយស្និទ្ធស្នាល នៅពេលដែលបុត្រធីតារបស់អស់លោកអ្នកវិលត្រឡប់មកកាន់គ្រួសារវិញ។

៥- ដឹកនាំបុត្រធីតារបស់លោកអ្នកឱ្យនិយមល្បែងកំសាន្តណាដែលមានប្រយោជន៍ ដូចជាការដឹកនាំឱ្យ

ចូលចិត្តគូរគំនូរ អានសៀវភៅល្អៗ ចូលចិត្តលេងល្បែងគ្រឿងម៉ាស៊ីន ចូលចិត្តបំពេញការងារដែលត្រូវដាក់ឱ្យធ្វើ ។

៦- ញញឹមទៅកាន់បុត្រធីតារបស់អស់លោកអ្នកពេលគេមានជ័យជំនះក្នុងការរៀនសូត្រ ហើយសូមលោកអ្នក កុំញញើតនឹងថ្លែងសេចក្តីសរសើរចំពោះជ័យជំនះទាំងនោះ ។

៧- សូមអស់លោកអ្នកបង្ហាញបុត្រធីតារបស់លោកអ្នកថា លោកអ្នកចូលចិត្តស្តាប់នូវរឿងរ៉ាវទាំងឡាយដែលបុត្រធីតារបស់អ្នកជំណាលប្រាប់ដោយរីករាយ ។

៨- តាមវិធីអប់រំ ការជេរ វាយ ស្តីបន្ទោស បានលទ្ធផលអាក្រក់ច្រើនជាងល្អ ។

៩- សូមលោកអ្នកឆ្លៀតឱកាសខ្លះ ដើម្បីទុកពេលសម្រាប់សំណេះសំណាលជាមួយបុត្រធីតារបស់លោកអ្នក ។

១០- សូមអស់លោកអ្នកឧស្សាហ៍សាកសួរអំពីសេចក្តីត្រូវការ អំពីសកម្មភាពរៀនសូត្រនៃបុត្រធីតារបស់លោកអ្នកជារឿយៗ ។

១១- សូមលោកអ្នកគ្រោងគិតនូវសេចក្តីត្រូវការរបស់បុត្រធីតាគ្រប់វិស័យ ដូចជាលោកអ្នកបម្រុងអាវក្រាស់សម្រាប់ខែរងា ទិញសៀវភៅណាដែលបុត្រធីតារបស់លោកអ្នកចង់បាន មុនពេលដែលបុត្រធីតារបស់លោកអ្នកឱ្យដំណឹងដល់អស់លោកអ្នក ។

១២- ដឹកនាំឱ្យមានទម្លាប់ល្អ ចេះស្រឡាញ់ការសម្អាត រៀបចំលំនៅស្ថានរបស់ខ្លួន ព្រោះការស្រឡាញ់ផ្ទះសំបែងនេះហើយដែលធ្វើឱ្យបុត្រធីតាលោកអ្នកចេះស្រឡាញ់មាតាបិតា ចេះស្រឡាញ់គ្រួសារ ចេះស្រឡាញ់ចូលចិត្តធ្វើការងារអ្វីៗទាំងអស់ ឱ្យបានស្អាតស្អំដែលជាមធ្យោបាយអាចនាំបុត្រធីតារបស់លោកអ្នកឱ្យមានអនាគតល្អ ។

១៣- បរិច្ចាគនូវកម្លាំងកាយ កម្លាំងទ្រព្យ និងពេលវេលា ដើម្បីនឹងរៀបចំអនាគតរបស់បុត្រធីតាលោកអ្នកឱ្យបានត្រចះត្រចង់ ។

១៤- ទៅជួបគ្រូរបស់កូនលោកអ្នក នៅថ្ងៃប្រជុំមាតាបិតាសិស្ស លោកអ្នកនឹងដឹងរឿងដែលលោកអ្នកមិនធ្លាប់ដឹងពីកូនរបស់លោកអ្នក ។

គំនិតខ្លីៗខាងលើនេះ អាចជួយសាងអនាគតបុត្រធីតារបស់លោកអ្នកបាន ។ យើងសូមចូលរួមចំណែកត្រេកអរជាទីបំផុតក្នុងករណីដែលបុត្រធីតារបស់លោកអ្នកមានអនាគតល្អត្រចះត្រចង់ ។

លោក ចែម ផាន

សាស្ត្រាចារ្យប្រវត្តិវិទ្យា

៙📖៚

# ជីវិត និងសេចក្ដីស្លាប់

មានជីវិត មានន័យថា រស់ដែលផ្ទុយនឹងស្លាប់។ រស់ និងស្លាប់ជាបញ្ញត្តិពីរដែលមិនជួបគ្នាជារៀងរហូត។ រស់ស្ថិតនៅប៉ូលម្ខាង រីឯស្លាប់ស្ថិតនៅប៉ូលម្ខាងទៀត។ បើរស់ គឺអត់ស្លាប់។ បើស្លាប់ គឺអត់រស់។ មនុស្សគ្រប់គ្នាមានសេចក្ដីស្លាប់ផ្ទាល់រៀង១ខ្លួន ដែលមិនអាចចែករំលែកឱ្យគ្នាបានឡើយ។ ថ្ងៃនេះ គេស្លាប់ អាត្មាអញនៅរស់ពុំទាន់ស្លាប់ទេ។ ប៉ុន្តែត្រូវដឹងដែរថា អាត្មាអញនឹងត្រូវស្លាប់ដូចគេនេះដែរនៅថ្ងៃណាមួយ។ ថ្ងៃដែលអាត្មាអញស្លាប់ អ្នកផ្សេងទៀតនៅរស់។ រាល់វិនាទី រាល់នាទី រាល់ម៉ោង រាល់ថ្ងៃ រាល់ខែ រាល់ឆ្នាំ មានអ្នកស្លាប់ជាបន្តបន្ទាប់ ហើយទន្ទឹមនោះក៏មានអ្នកកើតថ្មីជាបន្តបន្ទាប់គ្នាដែរ។ កាលណាគេឮពាក្យថា ស្លាប់ ឬនិយាយពីស្លាប់ គេមានការភ័យខ្លាចខ្លាំងណាស់។ មានក្រុមជនខ្លះ ដោយភ័យខ្លាចស្លាប់ពេក បានរិះរកមធ្យោបាយផ្សេង១ បង្កើតជាឧបករណ៍កំសាន្តលំហែសប្បាយច្រើនសំបូរបែប : ទូរទស្សន៍ វីដេអូ បារ ខារ៉ាអូខេ រាំវង់ ស្រែកច្រៀង ល្បែងស៊ីសង ស្រីស្រាអូនបង គ្រឿងញៀន... ដើម្បីបំភ្លេចសេចក្ដីស្លាប់។ ទីបំផុត នៅតែស្លាប់ដដែលជាដដែល។ ស្លាប់ គឺស្លាប់ មិនអាចគេចផុតឡើយ។

តាមទស្សនវិជ្ជា "តាវនិយម" ជីវិតប្រៀបដូចជាស្នប់ដែលគេសប់ឱ្យមានខ្យល់ចេញចូល (មានខ្យល់ គឺមានជីវិត)។ នៅពេលណាមួយដែលគេឈប់សប់ ខ្យល់ក៏លែងមាន ពេលនោះជីវិតក៏លែងមាន នោះហើយគឺ ស្លាប់។ តាមទស្សនៈកំណត់និយម ឬព្រហ្មលិខិតនិយមបានឱ្យដឹងថា ឈ្មោះ ជីវិត និងការស្លាប់របស់យើងម្នាក់១ត្រូវបានយមរាជកត់ត្រាទុកនៅលើទំព័រសៀវភៅ "ស្លាប់" រួចហើយ។ រៀងរាល់ថ្ងៃ យមរាជបើកសៀវភៅនោះ១ទំព័រម្ដង១។ បើបើកទៅចំលើអ្នកណា គឺជាថ្ងៃស្លាប់របស់អ្នកនោះហើយ មិនអាចគេចផុតឡើយ ទោះបីអ្នកនោះជាអ្នកណាក៏ដោយ ឬនៅទីណាក៏ដោយ។

ចូរកុំតក់ស្លុតខ្លាចសេចក្ដីស្លាប់ឱ្យសោះ ពីព្រោះវាជាធម្មជាតិសម្រាប់មនុស្សគ្រប់គ្នា។ កាលណាមានរូប មានជីវិតគឺត្រូវឆ្លងកាត់លំនាំជីវិតមួយដែលមានចំណុចចាប់ផ្ដើម និងចំណុចបញ្ចប់ (សម្រាប់ពង្សផៅមនុស្សជាតិ):

**ចំណុចចាប់ផ្ដើម (កើត) ⟶ ការរីកធំធាត់ (ចាស់, ជរា, ព្យាធិ) ⟶ ចំណុចបញ្ចប់(ស្លាប់)**

អ្នកណាក៏ដោយ មិនអាចចៀសផុតពីស្លាប់បានឡើយ គឺគ្រាន់តែមានរបៀបស្លាប់ និងពេលវេលាស្លាប់ផ្សេង១គ្នាតែប៉ុណ្ណោះ ពោលគឺអ្នកខ្លះស្លាប់ពីក្មេង អ្នកខ្លះដល់ធំដល់ចាស់បានស្លាប់ អ្នកខ្លះស្លាប់ដោយជំងឺ អ្នកខ្លះស្លាប់ដោយគ្រោះថ្នាក់ផ្សេង១ អ្នកខ្លះស្លាប់ថ្ងៃនេះ អ្នកខ្លះស្លាប់ថ្ងៃស្អែក...។

នៅក្នុងសៀវភៅទស្សនៈវិជ្ជារបស់លោក Huisman បានសរសេរថា យើងទាំងអស់គ្នាជាអ្នកទោសប្រហារជីវិត ព្រោះមច្ចុរាជបានកាត់ទោសប្រហារជីវិតយើងរាល់គ្នារួចហើយ រង់ចាំតែដល់ថ្ងៃត្រូវប្រហារ (សម្លាប់) តែ

ប៉ុណ្ណោះ ឬនិយាយម្យ៉ាងទៀតថា យើងទាំងអស់គ្នាបានស្លាប់រួចទៅហើយ ពីព្រោះយើងទាំងអស់គ្នានឹងត្រូវស្លាប់ដោយចៀសពុំរួចឡើយ។ យើងខំធ្វើអ្វីៗសព្វបែបយ៉ាងដើម្បីរង់ចាំសេចក្ដីស្លាប់ ឬដើម្បីធ្វើដំណើរបន្តិចម្ដងៗទៅរកសេចក្ដីស្លាប់តែប៉ុណ្ណោះ។ កើតមកតែម្ដងក្នុង១ជាតិ រួចស្លាប់ទៅវិញក៏តែម្ដងដែរក្នុង១ជាតិនេះ។

នៅក្នុងលោកនេះអ្វីៗប្រែប្រួលមិនទៀងទាត់ឡើយ ដូចព្រះពុទ្ធបានសម្ដែងថា អនិច្ចះ។ ប៉ុន្តែសេចក្ដីស្លាប់ទៀងទាត់ណាស់ តែដល់ថ្ងៃ ដល់ខែ ដល់ឆ្នាំកំណត់ហើយ គឺត្រូវតែស្លាប់ហើយ ចៀសមិនផុតទេ។

នរណាក៏ស្រឡាញ់ជីវិតដែរ គ្មាននរណាម្នាក់ចង់ស្លាប់ទេ។ ជីវិតពុំមានដាក់លក់ទេ។ ជីវិតអ្នកមានក្ដី ជីវិតអ្នកក្រក្ដី មានតម្លៃដូចគ្នា ពីព្រោះថាអ្នកណាក៏ស្រឡាញ់ជីវិត មិនចង់ស្លាប់ដូចតែគ្នា ទោះបីមានការលំបាកវេទនាក្នុងការរស់នៅក៏ដោយ។ នៅក្នុងល្បើកឡាហ្វុងតែន (La Fontaine) "សេចក្ដីស្លាប់ និងអ្នកកាប់អុស (La mort et le bûcheron) បានបញ្ជាក់ថា "plutôt souffrir que mourir, c'est la devise des hommes" មានន័យថា ទ្រាំលំបាកជាជាងស្លាប់ នេះគឺជាបាវចនារបស់មនុស្សលោក។ ពេលឈឺ យើងខំរកពេទ្យ រកថ្នាំព្យាបាលឱ្យឆាប់ជាសះស្បើយ ដើម្បីបន្តរស់តទៅទៀត និងបញ្ចៀសសេចក្ដីស្លាប់កុំឱ្យមកយាយីផ្ដាច់យកជីវិតយើងតែប៉ុណ្ណោះ។

នៅពេលសិក្សាទស្សនៈវិជ្ជាដំបូង លោកគ្រូបាននិយាយថា "La philosophie nous apprend à vivre et à mourir facilement" មានន័យថា ទស្សនវិជ្ជាបង្រៀនយើងឱ្យចេះរស់ និងឱ្យចេះស្លាប់យ៉ាងងាយស្រួល។ នៅក្នុងបរិបទនេះ មានតែព្រះធម៌ព្រះពុទ្ធទេដែលត្រូវលើកយកមកប្រតិបត្តិ ពីព្រោះព្រះពុទ្ធនៃយើងបានរកឃើញផ្លូវ និងបានចង្អុលបង្ហាញផ្លូវសម្រាប់រស់ និងសម្រាប់ស្លាប់រួចអស់ហើយ។

នៅក្នុងមួយជាតិរបស់យើងនេះ មានការជួបជុំគ្នា២លើកសំខាន់ជាងគេបំផុត គឺ១ជាការជួបជុំគ្នាប្រកបដោយសេចក្ដីសប្បាយរីករាយនៅពេលរៀបមង្គលការរបស់យើងដែលរូបយើងនៅរស់។ រីឯការជួបជុំលើកទី២ គឺជាពិធីបុណ្យខ្មោចរបស់យើងដែលមិនមានវត្តមានរបស់យើងទេ ពីព្រោះយើងបានស្លាប់បាត់ទៅហើយ។ គឺជាធិពីជួបជុំក្រៀមក្រំមានទុក្ខព្រួយធំធេងបំផុត។

ចូរយកធម៌ព្រះពុទ្ធមកប្រតិបត្តិ : រូបំអនិច្ចំ រូបំទុក្ខំ រូបំអនត្តំ! ខ្លាចស្លាប់នៅតែស្លាប់! ដូច្នេះចូរកុំខ្លាចស្លាប់! មច្ចុរាជមិនទទួលការអង្វររបស់យើងទេ។

ដូច្នេះ ពេលនៅរស់ ចូរខិតខំកសាងអំពើល្អ ដើម្បីកេរ្តិ៍ឈ្មោះល្អរបស់យើងនៅបន្តរស់តទៅទៀត។ ទុកទៅកំពង់នៅ មានន័យថា យើងបានស្លាប់ទៅហើយមែនតែស្នាដៃល្អរបស់យើងដែលបានបន្សល់ទុកមិនស្លាប់ទេ គឺនៅបន្តរស់តទៅទៀត។

(នៅមានត)

លោក ប៉េខ ស៊ីមហួច



# ចិត្តវិទ្យាអប់រំ

## យល់ដឹងអំពីទារកភាព

### I- ទារកទើបនឹងកើត (កូនង៉ែត)

ទារកទើបនឹងកើត (កូនង៉ែត) អាចមើលឃើញ ស្តាប់ឮ និងអាចឆ្លើយតបទៅនឹងគំហើញ ទៅនឹងសំឡេង និងរំញោចឥន្ទ្រិយារម្មណ៍សំខាន់ៗទាំងឡាយបាន។

**១_រេផ្លិចរបស់ទារក**

ទារកទើបនឹងកើត មានលំដាប់រេផ្លិច ឬការឆ្លើយតបអឆន្ទៈទៅនឹងរំញោចខាងក្រៅ។ ក្នុងចំណោមរេផ្លិចទាំងនោះ មានរេផ្លិចខ្លះជួយទារកឱ្យរស់រានមានជីវិត ហើយរេផ្លិចខ្លះទៀតបានបាត់បង់ទៅវិញនៅក្នុងឆ្នាំទី១នៃជីវភាពរបស់ទារក។

**ប្រភេទរេផ្លិចរបស់ទារក (កូនង៉ែត)**

| រេផ្លិច | រំញោច | ការឆ្លើយតបរបស់ទារក | រយៈពេលនៃការសម្តែងចេញ |
|---|---|---|---|
| ពព្រិចភ្នែក | ពន្លឺចែងចាំងខ្លាំង, កំសួល, ខ្យល់បក់ចំមុខខ្លាំង | បិទភ្នែកទាំងពីរ | អចិន្ត្រៃយ៍ |
| Babinski | ប៉ះបាតជើងភ្លាមៗ | លាត្រដាងម្រាមជើង, ជើងរមួលចូលគ្នា | កើតមានក្រោយអាយុ៦ខែទៅ ១ឆ្នាំ |
| កាន់ក្តាប់ | ប៉ះបាតដៃ | ចាប់កាន់ ឬក្តាប់យ៉ាងណែន | ចុះខ្សោយក្រោយអាយុ៣ខែ បាត់ទៅវិញក្រោយអាយុ១ឆ្នាំ |
| កន្ត្រាក់ (Moro) | រំញោចកើតភ្លាមៗនៅពេលមានសម្លេងលាន់ឮខ្លាំង | ភិតភ័យ ភ្ញាក់កន្ត្រាក់ដៃជើង | បាត់ទៅវិញក្រោយអាយុ៣ខែ ទៅ៤ខែ |

| | | | |
|---|---|---|---|
| រាវរក ឬឈ្ងុស ឈ្ងុលរក | ប៉ះថ្ពាល់ ឬមាត់ប៉ះនឹងអ្វីមួយ ភ្លាមៗ | ងាកក្បាលបែរទៅរកភ្លាម ហាមាត់ ចាប់ផ្ដើមជញ្ជក់ភ្លាម | បាត់ទៅវិញក្រោយអាយុ៣ខែ ទៅ៤ខែ |
| លើកជើង. បោះជំហាន | បាតជើងប៉ះនឹងផ្ទៃអ្វីមួយ ឈរលើផ្ទៃអ្វីមួយ | ជើងមានចលនាហាក់ដូចជា ចង់លើក ឬឈានដើរ | បាត់ទៅវិញក្រោយអាយុ៣ខែ ទៅ៤ខែ |
| ជញ្ជក់ | មានអ្វីប៉ះមាត់ | ជញ្ជក់ដោយស្វ័យប្រវត្តិ | បាត់ទៅវិញក្រោយអាយុ៣ខែ ទៅ៤ខែ |

## ២_សភាវៈទាំងឡាយរបស់ទារកទើបនឹងកើត

ទារកអាចផ្លាស់ប្ដូរសភាវៈ ឬអាចធ្វើឱ្យលំនាំនៃកម្រិតសកម្មភាពកើតមានឡើងវិញដោយគិតចាប់តាំងពីសកម្មភាពភ្ញាក់ពីដំណេក រហូតដល់ពេលគេងលង់លក់ស្ងាត់ស្ងៀម ។ សភាវៈសំខាន់ ២ យ៉ាងរបស់ទារកទើបនឹងកើត គឺការដេក និងការយំ ។

<u>ក_ការដេក</u> : ទារកទើបនឹងកើត មិនដឹងពេលណាជាពេលយប់ និងពេលណាជាពេលថ្ងៃទេ ។ ទារកទើបនឹងកើតគេងច្រើនម៉ោងណាស់ ជាមធ្យមគឺ ១៦ទៅ១៧ម៉ោងក្នុង១ថ្ងៃ នៅក្នុងខែទី១នៃជីវិតរបស់គេ ។

ទ្រឹស្ដីស្វ័យបង្កើនកម្លាំងធាតុបានបង្ហាញថា ទារកចំណាយពេលគេងច្រើនជាងមនុស្សធំ២ដង ។ ដោយសារដំណេកនេះ ធ្វើឱ្យប្រព័ន្ធប្រសាទកណ្ដាលរបស់ទារកវិកលូតលាស់ ។

<u>ខ_ការយំ</u> : ការយំរបស់ទារកចាប់ផ្ដើមកើតមានតាំងពីពេលប្រសូត្រចេញពីផ្ទៃម្ដាយភ្លាមមកម្ល៉េះ ។ នេះគឺជាការយំទី១របស់ទារកដែលជាសញ្ញាប្រាប់ដល់ម្ដាយ និងឆ្មប ឬគ្រូពេទ្យឱ្យដឹងថា សួតរបស់ទារកពោរពេញដោយខ្យល់ ។

តាមការសិក្សារបស់អ្នកឯកទេសបានសម្គាល់ឃើញថា ទារកមានរបៀបយំ បី ប្រភេទ :

១-យំសំខាន់ : នៅពេលឃ្លាន នៅពេលងុយគេង នៅពេលភ្ញាក់ពីគេង...។

២-យំខឹង : នៅពេលទាស់ចិត្ត ឬការដោះស្រាយតម្រូវការមានការយឺតយ៉ាវដូចជា យឺតយ៉ាវក្នុងការឱ្យបៅជាដើម...។

៣-យំឈឺចុកចាប់ : នៅពេលវិញ្ញោចនៃការឈឺចាប់មានកម្រិតខ្ពស់ដូចជា ឈឺពោះ សត្វល្អិតខិច ឬខាំជាដើម...។

### តើត្រូវលួងទារកឱ្យស្ងៀមតាមរបៀបណា?

ការលួងឱ្យបាត់យំមានភាពខុសគ្នាតាមប្រភេទទារកដូចជា ភេទ ជាតិសាសន៍ និងតាមបច្ចេកទេសនៃការថែទាំ។ ក្នុងការលួងនេះ គេកត់សម្គាល់ឃើញថា ការបំពេរ ការដាក់កូនក្នុងអង្រឹងយោលតិចៗ ការលើកបី ការដាក់ទារកបញ្ឈរឱ្យកើយលើស្មារួចទះគូទតិចៗ ការឱ្យបៅ បានទទួលលទ្ធផលល្អ ដើម្បីធ្វើឱ្យទារកនៅស្ងៀម ។ ទារកក៏អាចជួយខ្លួនគេឱ្យនៅស្ងៀមបានដែរ ដោយការជញ្ជក់មេដៃ ឬជញ្ជក់ក្បាលដោះកៅស៊ូ ។

## II- សមត្ថភាពឥន្ទ្រិយារម្មណ៍ និងប្រត្យក្សារម្មណ៍របស់ទារក

### ១.សោតវិញ្ញាណ (ការស្ដាប់ឮ)

ចាប់តាំងពីកំណើតមក ទារកញ្ញោចណាស់ទៅនឹងសូរសំឡេងខ្លាំងៗ ជាងសូរសំឡេងខ្សោយ។ តែសូរសំឡេងខ្លាំងល្មមធ្វើឱ្យទារកចាប់យកបានងាយស្រួលជាង។ សោតវិញ្ញាណរបស់ទារកទើបនឹងកើត រីកលូតលាស់ល្អណាស់។ ទារកអាចចាប់យកប្រភេទនៃសូរសំឡេងខុសៗគ្នា និងអាចដឹងអំពីទិសនៃប្រភពសូរសំឡេងទៀតផង។ ទារកបានត្រៀមខ្លួនផងដែរ ដើម្បីផ្សាំទៅនឹងសំឡេងរបស់មនុស្ស។ នេះជាលក្ខណៈសម្បត្តិល្អប្រសើរសម្រាប់ការរីកចម្រើនផ្នែកសង្គម និងភាសារបស់ទារក នាពេលខាងមុខ។

### ២.ចក្ខុវិញ្ញាណ (ការមើលឃើញ)

សមត្ថភាពនៃការមើលឃើញរបស់ទារក នៅតែបន្តរីកលូតលាស់ចាប់ពីឆ្នាំទី១ នៃជីវិតរបស់គេ។ ទារកញ្ញោចទៅនឹងភាពចែងចាំងនៃពន្លឺ និងចលនា។ ទារកអាចសម្គាល់ និងញែកពណ៌បាន ព្រមទាំងអាចចាំបានដោយមិនច្រឡំគ្នានូវវត្ថុមានចលនាទាំងឡាយទៀតផង។ ទារកទើបនឹងកើតមិនទាន់អាចលៃតម្រូវភ្នែករបស់គេឱ្យបានត្រូវល្អទៅនឹងចម្ងាយឆ្ងាយៗនៅឡើយទេ។ ប៉ុន្តែភាពមុតនៃគំហើញរបស់គេកាន់តែល្អប្រសើរឡើង នៅក្នុងរយៈពេល៣ខែដំបូងនៃជីវិតរបស់គេ។ ក្នុងរយៈពេលនេះដែរ ទារកកាន់តែមានសមត្ថភាព ដើម្បីធ្វើប្រត្យក្សារម្មណ៍ទៅលើលំអាននៃកម្មវត្ថុទាំងឡាយដែលក្នុងនោះមានលំអាននៃតួមុខមនុស្សយើងផង។

ប្រត្យក្សារម្មណ៍ពិតប្រាកដអំពីចម្ងាយ រីកចម្រើនទៅតាមអាយុ គឺនៅពេលដែលទារកចាប់ផ្ដើមសម្របសម្រួលភ្នែកទាំងពីររបស់គេឱ្យស៊ីសង្វាក់គ្នា និងចេះប្រើគំហើញស្តេរ៉េអូស្កូពិក។ តាមពិសោធន៍ដែលទាក់ទងទៅនឹងគំហើញនេះបានបង្ហាញឱ្យដឹងថា នៅពេលដែលកុមារមានអាយុចន្លោះពី៦ខែទៅ១៤ខែ ពួកគេអាចធ្វើប្រត្យក្សារម្មណ៍បានទូលំទូលាយដែលទាក់ទងទៅនឹងថេរភាពរាង និងថេរភាពទំហំ។

### ៣.ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណ

ទារកទើបនឹងកើតអាចញែកក្លិនដាច់ពីគ្នាបាន ក្នុងចំណោមក្លិនជាច្រើន។ នៅអាយុទើបបាន១សប្ដាហ៍ ទារកបានស្គាល់ក្លិនម្ដាយច្បាស់ជាងក្លិនអ្នកដទៃ (ពិសេសក្លិនខ្លួនម្ដាយនៅពេលបៅ)។ ទន្ទឹមនោះ ទារកចេះញែករសជាតិផ្សេងៗដាច់ចេញពីគ្នា។ ពួកគេសម្ដែងចេញនូវការចូលចិត្តរសជាតិផ្អែមជាងរសជាតិជូរ ឬល្វីង។

ចំពោះសកម្មភាពនៃកាយវិញ្ញាណវិញ ទារកបានសម្ដែងចេញចាប់តាំងពីមុនពេលកើតម្ល៉េះ។ ដោយផ្អែកលើលទ្ធភាពនៃកាយវិញ្ញាណរបស់ខ្លួន ទារកបានចេះចាំ និងស្គាល់អង្គវត្ថុជាច្រើនបានយ៉ាងឆាប់រហ័ស។ (នៅមានត)

**លោក ម៉េង ស៊ីមហួង**

**អតីតនាយកមជ្ឈមណ្ឌលបច្ចេកទេស**

**និងវិជ្ជាជីវៈព្រះកុសុមៈ**

ដកស្រង់ចេញពីសៀវភៅ Child Development របស់លោក Santrock-USA

# ដំណាក់រងទាំង ៦ នៃដំណាក់ឥន្ទ្រីយ៍ចលករ របស់លោកព្យ៉ាហ្សេត៍ ស្តីអំពីការរីកចម្រើនពុទ្ធិរបស់កុមារ

ដំណាក់ឥន្ទ្រីយ៍ចលកររបស់លោកព្យ៉ាហ្សេត៍ ស្តីអំពីការរីកចម្រើនពុទ្ធិរបស់កុមារនេះជាដំណាក់ទី១នៃដំណាក់ធំ១ ទាំងបួនរបស់លោក ។

តាមលោកព្យ៉ាហ្សេត៍ ដំណាក់ឥន្ទ្រីយ៍ចលករចាប់គិតពីពេលកើតរហូតដល់អាយុ២ឆ្នាំ ។ នៅក្នុងដំណាក់នេះ ការរីកចម្រើនផ្លូវចិត្តរបស់កុមារសម្តែងចេញនូវលក្ខណៈពិសេសតាមវឌ្ឍនាការផ្ទៃក្នុងបំណិនរបស់គេ ដើម្បីរៀបចំ និងសម្របសម្រួលឥន្ទ្រីយារម្មណ៍ជាមួយចលនាកាយ និងអំពើ ឬសកម្មភាព ។ ដូច្នេះហើយទើបមានឈ្មោះថា ឥន្ទ្រីយ៍ចលករ ។

ដំណាក់ឥន្ទ្រីយ៍ចលករនេះបែកចេញជា ៦ ដំណាក់រង ។ ដំណាក់រងនីមួយៗជាប់ទាក់ទងទៅនឹងបម្លាស់ប្តូរគុណភាពនៃផ្នែកដំណាក់ទាំងឥន្ទ្រីយ៍ចលករ ។ នៅក្នុងទ្រឹស្តីរបស់លោកព្យ៉ាហ្សេត៍ មានគំនិតស្គីម (Scheme)(1) សំខាន់ណាស់ ។ ដំណាក់រងនីមួយៗតាងមានស្គីមខុសៗគ្នា ។ ឧទាហរណ៍ ៖ នៅដំណាក់រងទី១នេះ ភាគច្រើនស្គីមច្រើនតែជាវេធ្លិច ដូចជាការជញ្ជក់ ការឈ្ងុលរក ការពព្រិចភ្នែកជាដើម ។ ពីដំណាក់រងមួយទៅដំណាក់រងមួយទៀត ស្គីមផ្លាស់ប្តូរចំណាត់ថ្នាក់របស់វា ។ បម្លាស់ប្តូរនេះជាស្នូលនៃដំណាក់ធំ១ទាំង៤ របស់លោកព្យ៉ាហ្សេត៍ ។ ដំណាក់រងទាំង៦ នៃឥន្ទ្រីយ៍ចលករមាន ៖ ១-វេធ្លិចធម្មតា ២-ទម្លាប់ដំបូង និងប្រតិកម្មវិលវល់ទី១ ៣-ប្រតិកម្មវិលវល់ទី២ ៤-ការសម្របសម្រួលប្រតិកម្មវិលវល់ទី២ ៥-ប្រតិកម្មវិលវល់ទី៣ ភាពថ្មី និងការចង់ចេះចង់ដឹង ៦-ការច្នៃប្រឌិតទៅផ្ទៃក្នុងនៃស្គីម ។

## ១-វេធ្លិចធម្មតា

គឺជាដំណាក់រងឥន្ទ្រីយ៍ចលករទី១ របស់លោកព្យ៉ាហ្សេត៍ ដែលត្រូវនឹងខែទី១ ក្រោយថ្ងៃកំណើតរបស់ទារក ។ ក្នុងដំណាក់រងនេះ ការសម្របសម្រួលឥន្ទ្រីយារម្មណ៍ និងអំពើ គឺធ្វើតាមរយៈឥរិយាបថវេធ្លិច ដែលក្នុងនោះមានការឈ្ងុលរក និងការជញ្ជក់ដែលទារកធ្វើតាំងពីកំណើតមក ។ នៅដំណាក់នេះ ទារកមិនទាន់ប្រើវេធ្លិចទាំងអស់នេះ ។ សំខាន់ជាងនេះទៀត គឺទារកបានអភិវឌ្ឍបំណិនរបស់ខ្លួន ដើម្បីបង្កើតឥរិយាបថដែលស្រដៀងគ្នានឹងវេធ្លិចដែរ នៅពេលអវត្តមានវេធ្លិចជាក់ស្តែង ។ ឧទាហរណ៍ ៖ កូនខ្ចីអាចជញ្ជក់ទឹកដោះក្នុងដប ឬជញ្ជក់ប្រដាប់ជញ្ជក់តែនៅកាលណាដបទឹកដោះ និងប្រដាប់ជញ្ជក់ស្ថិតនៅជិតមាត់របស់គេ ។ ពេលពីពេលទើបនឹងកើត ដបទឹកដោះ ឬប្រដាប់ជញ្ជក់បង្កើតឲ្យមានឥរិយាបថជញ្ជក់របស់កូនខ្ចី តែកាលណាដបទឹកដោះ ឬប្រដាប់ជញ្ជក់នោះត្រូវបានដាក់ចូលទៅក្នុងមាត់ ឬធ្វើឱ្យប៉ះបបូរមាត់ទារកប៉ុណ្ណោះ ។ អំពើវេធ្លិច (នៅពេលពុំមានរំញោចកកើតឡើង) គឺជាភស្តុតាងបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ទារកកំពុងតែទម្លាប់ខ្លួន ធ្វើអំពើទាំងនោះ និងកំពុងតែធ្វើវចនាសម្ព័ន្ធបទពិសោធន៍របស់គេយ៉ាងសកម្មនៅអាយុ ១ខែដំបូង ។

(1) Scheme = ski:m អានថា ស្គីម ដែលក្នុងទ្រឹស្តីលោកព្យ៉ាហ្សេត៍មានន័យថា ជាអំពើ ឬចំណេះដឹងដែលរៀបចំបង្កើតពុទ្ធិ ។

## ២-ទម្លាប់ដំបូង និងប្រតិកម្មវិលវង់ទី១

នេះគឺជាដំណាក់កាលឥន្ទ្រីយ៍ចលករទី២ របស់លោកព្យ៉ាហ្សេត៍ ដែលលូតលាស់នៅអាយុចន្លោះ១ខែ និង៤ខែ។ ក្នុងដំណាក់កាលនេះ ទារករៀនដើម្បីសម្របសម្រួលឥន្ទ្រីយារម្មណ៍ និងប្រភេទទាំងឡាយនៃស្គីម ឬរចនាសម្ព័ន្ធដែលជាទម្លាប់ដំបូង និងជាប្រតិកម្មវិលវង់ទី១។ ទម្លាប់គឺជាស្គីមនៃវេជ្ជិចសាមញ្ញ ដូចជាការជញ្ជក់ជាដើម។ ឧទាហរណ៍ : នៅក្នុងដំណាក់កាលនេះ ទារកអាចជញ្ជក់បាន កាលណាដបទឹកដោះក្មេចមាត់ ឬក៏ភ្លេចភ្នែករបស់គេ។

ក្នុងដំណាក់កាលទី២នេះ ទារកហាត់ប្រើស្គីមនៃការជញ្ជក់បានដែរ ទោះបីជាពុំមានដបទឹកដោះក្មេចក៏ដោយ។ ប្រតិកម្មវិលវង់នេះ ជាស្គីមមួយដែលផ្អែកលើការខិតខំរបស់ទារក ដើម្បីបង្កើតឡើងវិញនូវហេតុការណ៍សំខាន់ ឬរីករាយណាមួយដែលបានកើតឡើងដោយចៃដន្យពីគ្រាដំបូងមក។ ទម្លាប់ និងប្រតិកម្មវិលវង់មានលក្ខណៈស្តេរេអូទីប (Stéréotype : ដែលធ្វើដដែលៗជាលក្ខណៈស្វ័យប្រវត្តិនៃអំពើ ឬអាកប្បកិរិយា) ដែលក្នុងនោះទារកធ្វើដដែលៗឡើងវិញតាមរបៀបដូចៗគ្នាក្នុងពេលនីមួយៗ។ រូបកាយរបស់កុមារស្ថិតនៅជាមជ្ឈមណ្ឌលនៃបម្រុងប្រយ័ត្នដដែល។ ក្នុងដំណាក់កាលទី២ នៃការអភិវឌ្ឍរបស់កុមារនេះជាប់ទាក់ទងទៅនឹងបញ្ញត្តិ "ប្រតិកម្មវិលវង់" ដែលលោកព្យ៉ាហ្សេត៍បានប្រើដើម្បីរៀបរាប់អំពីអំពើដដែលៗសាចុះសាឡើងដែលមានទម្រង់ផ្សេងៗគ្នា។

## ៣-ប្រតិកម្មវិលវង់ទី២

គឺជាដំណាក់កាលឥន្ទ្រីយ៍ចលករទី៣ របស់លោកព្យ៉ាហ្សេត៍ ដែលរីកលូតលាស់នៅអាយុចន្លោះ៤ខែ និង៨ខែ។ ក្នុងដំណាក់កាលនេះ កុមារមានការតម្រង់ទិសទៅរកកម្មវត្ថុច្រើនជាង ឬមានការផ្តោតអារម្មណ៍ទៅលើពិភពលោកខ្លាំងក្លា និងទូលំទូលាយជាង។ កុមារធ្វើត្រាប់តាមអំពើសាមញ្ញរបស់អ្នកផ្សេងទៀត ដូចជាការនិយាយរបស់កូនក្មេង ឬការនិយាយលេងរបស់មនុស្សធំ ហើយនិងធ្វើតាមកាយវិការរូបជាដើម។ ឆ្លងតាមការធ្វើត្រាប់តាមនេះ កុមារអាចបង្កើតបាននូវអំពើទាំងនេះ។ ថ្វីបើកុមារមានការតម្រង់ទិសទៅរកកម្មវត្ថុក្នុងពិភពលោកក៏ដោយ ក៏ស្គីមរបស់កុមារនៅមានកង្វះខាតគុណភាពដែរ ចំពោះគោលបំណងមួយដែលមានការកំណត់ទិសដឹកនាំជាមុននោះ។

## ៤-ការសម្របសម្រួលប្រតិកម្មវិលវង់ទី២

គឺជាដំណាក់កាលឥន្ទ្រីយ៍ចលករទី៤ របស់លោកព្យ៉ាហ្សេត៍ ដែលស្ថិតនៅអាយុចន្លោះ៨ខែ និង១២ខែ។ នៅដំណាក់កាលនេះ មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ជាច្រើនបានកើតឡើងដែលជាប់ទាក់ទងទៅនឹងការសម្របសម្រួលស្គីម និងបំណង ឬចេតនា។ កុមារបានបញ្ចូលគ្នា និងរៀបចំបញ្ចូលជាមួយគ្នាឡើងវិញយ៉ាងងាយ នូវស្គីមដែលបានចេះចាំពីមុនតាមវិធីសម្របសម្រួលមួយ។ ពួកគេអាចមើលឃើញកម្មវត្ថុមួយហើយយល់អត្ថន័យរបស់វាព្រមពេលជាមួយគ្នា។ ទាក់ទងនឹងការសម្របសម្រួលនេះ គឺការកើតមានបំណង ឬចេតនាបែងចែករវាងមធ្យោបាយ និងគោលបំណងដើម្បីធ្វើឱ្យសម្រេចវត្ថុបំណងងាយៗទាំងឡាយ។ ឧទាហរណ៍ : កុមារអាចប្រើបន្ទាត់ (មធ្យោបាយ) ដើម្បីឆ្កឹះយកប្រដាប់លេងមួយដែលគេចង់បាន (គោលបំណង) ដែលស្ថិតនៅក្នុងចម្ងាយអាចឆ្កឹះយកបាន។

## ៥-ប្រតិកម្មវិលវង់ទី៣ ភាពថ្មី និងការចង់ចេះចង់ដឹង

គឺជាដំណាក់កាលឥន្ទ្រិយ៍ចលករទី៥ របស់លោកព្យ៉ាហ្សេត៍ ដែលលូតលាស់នៅអាយុចន្លោះ១២ខែ និង១៨ខែ។ នៅក្នុងដំណាក់កាលនេះ កុមារមានការចង់ដឹងអំពីភាពប្លែកៗនៃលក្ខណៈរបស់កម្មវត្ថុ។ ឧទាហរណ៍ : ដុំប៊ូលមួយដែលគេធ្វើឱ្យធ្លាក់ វាអាចវិល វាអាចប៉ះ ទង្គិចជាមួយវត្ថុផ្សេងៗទៀត ហើយវាអាចរមៀលលើផ្ទៃដី។ ប្រតិកម្មវិលវង់នេះគឺជាស្តីមដែលកុមារខិតខំរុករកប្រកបដោយឆន្ទៈ អំពើអ្វីដែលធ្វើឱ្យមានការផ្លាស់ប្តូរជាបន្តបន្ទាប់នេះ និងអំពីលទ្ធផលរបស់វា។ លោកព្យ៉ាហ្សេត៍ បានលើកឡើងថា ដំណាក់កាលនេះបានគូសបញ្ជាក់នូវចំណុចចាប់ផ្តើមនៃការអភិវឌ្ឍ ការចង់ចេះចង់ដឹងរបស់មនុស្ស និងចំណូលចិត្តចំពោះភាពថ្មី។

ប្រតិកម្មវិលវង់នៅដំណាក់កាលមុន គឺទុកសម្រាប់តែការបង្កើតឡើងវិញនូវហេតុការណ៍ចាស់ៗពីមុនមកប៉ុណ្ណោះ ដោយពុំបានលើកយកការធ្វើត្រាប់តាមអំពើថ្មីៗដែលបានកើតមាននៅក្នុងដំណាក់កាលទី៤ឡើយ។ ប្រតិកម្មវិលវង់ទី៣នេះ ជាជំហានទី១ដែលបានគិតគូរអំពីភាពថ្មី។

## ៦_ការធ្វើឱ្យទៅជាផ្ទៃក្នុងនៃស្តីម

គឺជាដំណាក់កាលឥន្ទ្រិយ៍ចលករទី៦ និងជាដំណាក់ចុងក្រោយដែលរីកលូតលាស់នៅអាយុចន្លោះ១៨ខែ និង២៤ខែ។ ក្នុងដំណាក់កាលនេះ ដំណើរការសតិបញ្ញារបស់កុមារប្តូរពីកម្រិតឥន្ទ្រិយារម្មណ៍សុទ្ធសាធទៅជាកម្រិតនិមិត្តសញ្ញា ហើយដែលកុមារខិតខំអភិវឌ្ឍបំណិនរបស់ខ្លួន ដើម្បីប្រើប្រាស់និមិត្តសញ្ញាដំបូងនេះ។ ចំពោះលោកព្យ៉ាហ្សេត៍ និមិត្តសញ្ញាគឺជារូបភាពឥន្ទ្រិយារម្មណ៍ដែលបានធ្វើឱ្យទៅជាផ្ទៃក្នុងរួចហើយឬមួយក៏ជាពាក្យពេចន៍ដែលបានតាងហេតុការណ៍មួយ។

និមិត្តសញ្ញាដំបូងនេះជួយកុមារឱ្យចេះគិតអំពីហេតុការណ៍រូបីដោយពុំចាំបាច់ធ្វើអំពើផ្ទាល់ឬធ្វើប្រត្យក្សារម្មណ៍ផ្ទាល់ជាមួយឡើយ។ លើសពីនេះ និមិត្តសញ្ញាជួយកុមារឱ្យចេះប្រើ និងចេះបំប្លែងហេតុការណ៍ទាំងឡាយដែលបានតាងរួចហើយនោះតាមវិធីងាយៗទៀតផង។ ឧទាហរណ៍មួយរបស់លោកព្យ៉ាហ្សេត៍ បាននិយាយអំពីកូនស្រីតូចរបស់លោកដែលបានឃើញប្រអប់ឈើគូសកំពុងតែបើក និងបិទ។ លុះបន្តិចក្រោយមក នាងតូចក៏ធ្វើត្រាប់តាមហេតុការណ៍នោះដោយបើក និងបិទមាត់របស់នាង។ នេះគឺជាការសម្តែងចេញជាក់ស្តែងរបស់នាង នូវរូបភាពនៃហេតុការណ៍នោះ។

សន្និដ្ឋានរួម : អ្នកសិក្សាស្រាវជ្រាវមួយចំនួនបានយល់ឃើញថា នៅក្នុងដំណាក់ឥន្ទ្រិយ៍ចលករនេះ កុមារមានការអភិវឌ្ឍ ពីរ ផ្នែកគឺ :

១-ការអភិវឌ្ឍផ្នែកប្រត្យក្សារម្មណ៍

២-ការអភិវឌ្ឍផ្នែកទស្សនៈបញ្ញត្តិ ៕

**លោក ប៉េង ស៊ីមហួច**

**អតីតនាយកមជ្ឈមណ្ឌលបច្ចេកទេស**

**និងវិជ្ជាជីវៈព្រះកុសុមៈ**

ដកស្រង់ចេញពីសៀវភៅ Child Development របស់លោក John W.Santrock-University of Texas-USA




# តារារណបសម្រាប់ការគូរផែនទី

ការគាំងភូគោលតាមរយៈសិល្បៈនៃការគូរផែនទី បានបោះជំហានយ៉ាងសម្បើម ដោយសារអាកាសចរណ៍ តែការគាំងនេះត្រូវបានឆ្លងកាត់ដំណាក់ថ្មីមួយ នោះគឺតារារណបនានា។

ជាដំបូង តារារណបជាឧបករណ៍សារវ័ន្តសម្រាប់ការស្រាវជ្រាវខាងយោធា។ ឥឡូវនេះអ្នកភូមិវិទ្យា និងភូមិសាស្ត្រនិយមបានទទួលទិន្នន័យយ៉ាងសម្បូរបែប តាមរយៈឧបករណ៍ទាំងនេះផងដែរ។

ចាប់ពីឆ្នាំ១៩៧២ អាមេរិកបានបង្ហោះតារារណប Landsat I ដែលគន្លងវិថីរបស់វាមានកម្ពស់ ៩០០គម ពីផែនដី។ ប្រព័ន្ធនៃរបកគំហើញពីចម្ងាយផ្ដល់រូបភាពសំយោគចេញពីក្រុមឆាយាភូត ៤ ទំហំតូចបំផុតដែលអាចពិនិត្យបាន នោះគឺ៧០ម៉ែត្រលើផ្ទៃដី។ ក្រោយពីតារារណប Landsat I មានតារារណបច្រើនទៀត ដែលផ្ដល់ទិន្នន័យកាន់តែសុក្រិត។ នៅឆ្នាំ១៩៨៦ បារាំងបានរៀបចំប្រព័ន្ធសម្រាប់ពិនិត្យផែនដី SPOT (Système Pour l'Observation de la Terre) ដែលមានគន្លងវិថីកម្ពស់ ៨៣២គម ហើយវិលជុំមកកន្លែងដដែលវិញរៀងរាល់២៦ថ្ងៃ។ តមកទៀត មានតារារណប "Hélios" ឧបករណ៍កាន់តែមានលំនាំសាំញ៉ាំថែមទៀត។ ដោយសារការស្រាវជ្រាវដ៏ល្អិតល្អន់ តារារណបទាំងនោះបានធ្វើឱ្យការគូរផែនទីមានភាពប្រាកដប្រជាកាន់តែខ្លាំងឡើង។


ERS1 កសាងសម្រាប់ជាភ្នាក់ងារអវកាសអឺរ៉ុប និងកាណាដា ត្រូវបានបង្ហោះនៅស្ថានីយអារីយ៉ាន (Ariane) នាឆ្នាំ១៩៩១ ជាតារារណបសម្រាប់ចាប់យកព័ត៌មានពីចម្ងាយនូវទិន្នន័យយ៉ាងធំធេង និងបរិស្ថាន។

គម្រោងនៃការរៀបចំផែនទីតាមខ្នាតតូចក្ដី ធំក្ដី ត្រូវកសាងឡើងបានងាយស្រួលជាងពេលមុនៗ ដែលផែនទីត្រូវបានសម្គាល់ជាបែបសណ្ឋាននៃរូបភាពទេសភាពតែប៉ុណ្ណោះ។



បំពាក់ដោយបរិក្ខាយ៉ាងសុក្រឹត តារាវណបបានតាក់តែង វិទ្យាសាស្ត្រខាងធ្វើផែនទី (topographie) យ៉ាងប្រាកដប្រជា បំផុតអំពីបាតសមុទ្រ គំនូរកាត់នេះបង្ហាញតំបន់ ៥០០០គ.ម./ជ្រុង ហើយបានកំណត់ចាប់ពីចរិតលក្ខណៈពីផ្ទៃមហាសាគរ។

សក្ដានុភាពចម្បងនៃបច្ចេកទេសនេះ សម្រួលដល់ការរៀបចំព័ត៌មាននៅក្នុងពេលខាងមុខនេះ ដូចជាព័ត៌មានផ្ដល់ផលប្រយោជន៍ដល់យោធា ហើយជាក់ស្ដែងជាងនេះទៅទៀតដល់ឧតុភូតវិទ្យា ឬការស្រាវជ្រាវ និងការសិក្សាអំពីកង្វក់បរិស្ថាន។ សេចក្ដីសង្ឃឹមក្នុងការរៀបចំតារាវណប Topex-Poséidon ដែលបង្ហោះកាលពីខែសីហា ១៩៩២ សំដៅស្វែងយល់អំពីបាតុភូត "Nino" ចរន្តក្ដៅ ដែលតែងតែបណ្ដាលឱ្យមានការភ័ន្តប្រែអាកាសធាតុនៃឆ្នេរសមុទ្រប៉ាស៊ីហ្វិកដែលធ្វើឱ្យដឹងអំពីលទ្ធភាពផ្ដល់បានតាមរយៈទស្សនៈថ្មីនេះរបស់ ផែនដី។

តារាវណបកាន់តែច្រើនផ្សេងទៀត នឹងត្រូវបានបង្ហោះក្នុងឆ្នាំខាងមុខ និងពហុភាពនៃទិន្នន័យស្រង់បាននោះនឹងត្រូវបានបកស្រាយតាមនិយាមរលូនក្នុងលំដាប់ថ្នាក់ពិភពលោក។

ព័ត៌មានវិទ្យាទីនេះ សម្ដែងតួនាទីដ៏សំខាន់ ហើយកុំព្យូទ័របានផ្ដុំធ្វើឱ្យបានដូចដើមវិញនិងអាចមើលឃើញច្បាស់ពីចម្ងាយតាមតារាវណប។ ដូចនេះ វាបង្កលក្ខណៈងាយស្រួលដល់ការគូរផែនទីឱ្យមានលក្ខណៈដោយឡែក។ រូបភាពត្រូវធ្វើឱ្យក្លាយទៅតាមចរិតពិសេស។ ឧទាហរណ៍ចម្ងាយនានាត្រូវបានគាងទៅតាមពេលវេលា នៃគមនាគមន៍ មិនមែនទៅតាមបទដ្ឋាននៃការវាស់វែងផ្ទៃរាបនោះទេ។ សិល្បៈនៃការគូរផែនទីដោយមានជំនួយពីកុំព្យូទ័រ (CAO = Cartographie Assistée par Ordinateurs) បានធ្វើឱ្យមានការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សនៅពេលចុងក្រោយនេះ។



ផែនទីនេះត្រូវបានគូរទៅតាមទិន្នន័យដែលផ្ដល់ដោយតារាវណប។ វាផ្ដល់ព័ត៌មានអំពីល្បឿនខ្យល់។ តំបន់គ្មាន ខ្យល់ពណ៌ខៀវ ពណ៌ក្រហម ខ្យល់ល្បឿន៥ម/វ ពណ៌លឿង ១០ម/វ

នៅពេលអនាគត វានឹងអាចប្រែប្រួលយ៉ាងច្រើនទៀត មានទំនោរទៅរកភូមិវិទ្យាវិទូ ឬសង្គមវិទូ ដើម្បីយល់កាន់តែច្បាស់អំពីលំហូរនៃគមនាគមន៍ បំលាស់ទីនៃប្រជាជន ឬការវិវត្តន៍នៃទីក្រុង ៕

ប្រែសម្រួល : លោក តែង យ៉ារ

Encyclopédie des connaissances actuelles




## ទំនាញសូរ

ពាក្យពេចន៍ ស្នូរស្នៀង ទំនាញព្យាង្គរបស់អក្សរសាស្ត្រខ្មែរយើង ជាលទ្ធផលដែលចេញពីការកំណត់យ៉ាងជាក់លាក់មួយដែលយើងទាំងអស់គ្នាគួរតែស្វែងយល់ឱ្យបានច្បាស់ ដើម្បីចៀសវាងនូវកំហុសទាំងឡាយខាងអក្ខរាវិរុទ្ធ។ កំហុសដែលកើតពីការភ្លាំងភ្លាត់ ឬដោយអចេតនា ចាត់ទុកថា ជារឿងធម្មតាទៅចុះ ព្រោះដំរីជើងបួនគង់មានភ្លាត់ ប៉ុន្តែប្រសិនបើកំហុសឆ្គងទាំងនោះខុសទាំងមិនយល់អ្វីសោះនោះ គឺជារឿងមួយផ្សេងទៀត មិនអាចចាត់ទុកថាធម្មតាឡើយ។

ថ្ងៃនេះ ខ្ញុំលើកយកនូវពាក្យទំនាញសូរមួយចំនួន ដើម្បីគ្រាន់តែជាជំនួយដល់លោកគ្រូអ្នកគ្រូប៉ុណ្ណោះ ដោយជ្រើសយកតែពាក្យសំខាន់ៗខ្លះធ្វើជាគោលសម្រាប់ពាក្យដទៃទៀតដែលមានលក្ខណៈផ្ទុយគ្នាដោយសំឡេងពីរ គឺ ពួក អ និងពួកអ៊ ។

ជាធម្មតា ទំនាញសូរប្រព្រឹត្តទៅតាមសំឡេងរបស់ព្យញ្ជនៈពួកអ ឬអ៊ របស់ព្យាង្គនីមួយៗដូចតទៅនេះ :

- បើព្យាង្គទីមួយជាព្យញ្ជនៈពួកអ ទាញព្យាង្គទីពីរជាព្យញ្ជនៈពួកអ៊ ឱ្យមកជាសំឡេង អ បាន ដោយមិនបាច់ប្រើមូសិកទន្ត ( ៊ )(សញ្ញា អ) ។ ឧទាហរណ៍ : សំរាម កំរាល ករី ស្វាមី ស្រមោច ។ល។
- បើព្យាង្គទីមួយជាពួក អ៊ ទាញព្យាង្គទីពីរជាព្យញ្ជនៈពួក អ ឱ្យមកជាសំឡេងពួក អ៊ បានដោយមិនបាច់ប្រើត្រីសព្ទ ( ៊ ) សញ្ញា អ៊ ។ ឧទាហរណ៍ : ទាហាន ជំហរ វិហារ ។ល។
- ពាក្យខ្លះមិនអាចមានទំនាញសូរឡើយ ព្រោះព្យាង្គនៃព្យញ្ជនៈរបស់ពាក្យនោះមានសំឡេងដូចគ្នា បើពួក អ៊ គឺ អ៊ ទាំងពីរ បើពួក អ គឺ អ ទាំងពីរ ។ ឧទាហរណ៍ : ភ៊ុរ៉េ ប៉េងប៉ោះ ប៉េងប៉ោង កៅស៊ូ ។ល។ ត្រូវរក្សាទុកមូសិកទន្ត ឬត្រីសព្ទដដែល ។
- ពាក្យខ្លះទៀតជានាមអសាធារណៈ និងពាក្យកំចីបរទេសគ្មានទំនាញសូរដែរ ដូចជា សារី សារុន សារ៉ាំ បូរី បូរ៉ី អេឡិចត្រូនិច តិចណូឡូស៊ី ។ល។ ពាក្យទាំងនេះសំដៅយកតែឈ្មោះប៉ុណ្ណោះ ។
- មានពាក្យដទៃទៀតក៏គ្មានទំនាញសូរដែរ ព្រោះពាក្យទាំងនោះជាពាក្យបន្សំ ។ ឧទាហរណ៍ : ស្រែកហៅ

កូនង៉ា ត្រីរស់ ។ល។ ចំពោះពាក្យត្រីរស់ ប្រសិនបើពាក្យនេះមានទំនាញសូរវិញ ន័យនៃពាក្យនេះនឹងក្លាយទៅជាត្រីមិនទាន់ស្លាប់ ។

តទៅនេះ គឺជាច្បាប់ទំនាញសូរដែលខ្ញុំលើកយកមកដើម្បីធ្វើជាគោលនៃពាក្យដទៃទៀត ដើម្បីជាជំនួយដល់អ្នកអានទាំងអស់ ។

**ទំនាញទី១**

ព្យាង្គទី១ នៃព្យញ្ជនៈ កខ ចឆ ដឋ តថ បផ និងសអ ។ ព្យញ្ជនៈទាំងនេះអាចទាញព្យាង្គទី២ នៃព្យញ្ជនៈ ង ញ ន ម យ រ ល វ ។ ដោយមិនបាច់ប្រើមូសិកទន្ត ឬធ្មេញកណ្ដុរឡើយ ។ ឧទាហរណ៍ : ក្រងក់ ចម្ងល់ ស្រងៃ ក្រញី ក្រញាប់ កំន ក្រមុំ ចំណង ប្រយោល ស្រយាល ចម្រាញ់ ចម្រើន ស្រវា ស្រវឹង ។ល។

**ទំនាញទី២**

ព្យាង្គទី១ នៃព្យញ្ជនៈ គ ជ ទ ព អាចទាញព្យញ្ជនៈ ហ នៅព្យាង្គទី២ ទៅជា ហ៊ ដោយមិនបាច់ប្រើត្រីសព្ទ ។ ឧទាហរណ៍ : គំហើញ ជំហាន ទំហំ វិហារ ។

ពាក្យទំនាញសូរដែលខ្ញុំលើកយកមកនេះ គ្រាន់តែជាជំនួយប៉ុណ្ណោះ មិនមែនដាច់ខាតទាំងស្រុងឡើយ សូមលោកគ្រូអ្នកគ្រូស្វែងយល់ឱ្យបានច្រើនទៀតដោយខ្លួនឯងផងចុះ ៕

លោក ឈាត ផេង

គ្រូបង្រៀនវិ.ដំដែក

ស្រុកសូទ្រនិគម ខេត្តសៀមរាប

---

**ស្រទាប**

| | |
|---|---|
| ស្រវឹងនឹងជីវិត...ភ្លេចងាប់ | ស្រវឹងនឹងទ្រព្យ...ភ្លេចខ្លួន |
| ស្រវឹងនឹងភាពមាំមួន...ភ្លេចអនិច្ចំ | ស្រវឹងនឹងកម្លាំង...ភ្លេចរោគ |
| ស្រវឹងនឹងលោក...ភ្លេចលាញ[១] | ស្រវឹងនឹងជំនាញ...ភ្លេចប្រយ័ត្ន |
| ស្រវឹងនឹងសម្បត្តិ...ភ្លេចសីលទាន | ស្រវឹងនឹងមាន...ភ្លេចក្រ |
| ស្រវឹងនឹងត្រាច់ចរ...ភ្លេចផ្ទះសម្បែង | ស្រវឹងនឹងក្មេង...ភ្លេចចាស់។... |

បទពិចារណា

(១)លាញ=(កិ.) ខូច វិនាស អន្តរាយ។

# មូលភេទ អ-អ៊ (ត)

## ៣-បដិសំយោគភាពក្នុងពាក្យ

ក្នុងភាសាខ្មែរ យើងពិនិត្យឃើញមានទំនាក់ទំនងបដិសំយោគរវាងព្យញ្ជនៈនិងស្រៈ រវាងព្យញ្ជនៈនិងព្យញ្ជនៈ រវាងព្យាង្គនិងព្យាង្គ។ បដិសំយោគភាពនេះ កើតឡើងដោយសារភាពកប់គូរបស់ស្រៈ និងដោយសារមូលភេទ អ-អ៊។ នៅទីនេះ យើងពិនិត្យមើលបដិសំយោគភាពដែលកើតឡើងដោយសារមូលភេទអ-អ៊។

### ៣.១-តើព្យញ្ជនៈណាខ្លះទទួលមូសិកទន្ត ( ៉ ) និងត្រីសព្ទ ( ៊ )

តាមរយៈសៀវភៅបោះពុម្ពផ្សាយកន្លងមក អ្នកវេយ្យាករណ៍ជាច្រើនបានយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាប្រើមូសិកទន្ត និងត្រីសព្ទនេះ។ អ្នកវេយ្យាករណ៍ទាំងនោះមានជាអាទិ៍ ÷

ក-លោក សៀង ខ័នឌី ក្នុងសៀវភៅ "នវវេយ្យាករណ៍ និងខេមរភាសា"

- ទំព័រ១៥១ ពន្យល់ថា មូសិកទន្ត ឬធ្មេញកណ្ដុរ ( ៉ ) សម្រាប់ប្រើបំបែរសំឡេងព្យញ្ជនៈ ៧តួ គឺ ង ញ ប ម យ រ វ ជាអឃោសៈ ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉។
- ទំព័រ១៥២ ពន្យល់ថា ត្រីសព្ទ ( ៊ ) ញ៉ាំងព្យញ្ជនៈសំឡេងគ្រលួចខ្លះ ឱ្យទៅជាព្យញ្ជនៈសំឡេងគ្រលរ ហើយប្រើបានលើព្យញ្ជនៈសំឡេងគ្រលួចចំពូកខ្លះ គឺ ប ស ហ អ ឱ្យទៅជា ប៊ ស៊ ហ៊ អ៊។

ខ-លោក អៀវ កើស ក្នុងសៀវភៅ "ភាសាខ្មែរ"

- ទំព័រ៤៤ ពន្យល់ថា...ព្យញ្ជនៈដែលសម្លាប់បាននោះ គឺព្យញ្ជនៈចុងវគ្គ៣ ÷ ង ញ ម និងព្យញ្ជនៈ អវគ្គ៣÷ យ រ វ។
- ទំព័រ៤៦ ពន្យល់ថា ...ព្យញ្ជនៈគ្រលួចចំពូកនេះបានដល់ ប ស ហ អ ដែលទៅជា ប៊ ស៊ ហ៊ អ៊។

គ-សៀវភៅវចនានុក្រមខ្មែរភាគ ១ ទំព័រ ៩០៣ ពន្យល់ថា ...ធ្មេញកណ្ដុរ ( ៉ ) នេះសម្រាប់ប្រើសម្លាប់បំបែរសំឡេងព្យញ្ជនៈ ៩តួ គឺ ង ញ ន ប ម យ រ ល វ ឱ្យមានសំឡេងជា ង៉ ញ៉ ន៏ ប៉ ម៉ យ៉ រ៉ ល៉ វ៉។ នៅឯទំព័រ៣៧៤ មាន ពន្យល់ថា ...ត្រីសព្ទ ( ៊ )នេះសម្រាប់ប្រើដាក់លើអក្សរ ៤តួ គឺ ប ស ហ អ ឱ្យមានសំឡេងធំជា ប៊ ស៊ ហ៊ អ៊។

តាមរយៈសៀវភៅខាងលើ យើងឃើញថា ការសិក្សាក្នុងវចនានុក្រមខ្មែរភាគ១ មានលក្ខណៈគ្រប់គ្រាន់។ យើងត្រូវតែបន្ត ស្នាដៃនោះតទៅទៀត។

### ៣.២-ឥទ្ធិពលរវាងមូលភេទទាំងពីរ

#### ៣.២.១-ក្បួនឥទ្ធិពលមូលភេទ (ឬក្បួនទំនាញសូរ)ពីសម័យមុន

អ្នកវេយ្យាករណ៍ខ្មែរយើងពីសម័យមុន បានសិក្សាបញ្ហាឥទ្ធិពលមូលភេទ អ-អ៊ គួរឱ្យចាប់អារម្មណ៍។ សៀវភៅវេយ្យាករណ៍ខ្មែរភាគច្រើនបានពន្យល់ក្បួនឥទ្ធិពលមូលភេទ (ទំនាញសូរ) យ៉ាងក្បោះក្បាយ ហើយជំនាន់ក្រោយៗបានអនុវត្តតាមក្បួនទាំងនោះរហូតមកដល់ថ្ងៃនេះយ៉ាងត្រឹមត្រូវ។

ក-លោក ពូវ អ៊ុម ក្នុងសៀវភៅ "វេយ្យាករណ៍ខ្មែរ" សម្រាប់បឋមសិក្សាបានណែនាំនៅទំព័រ២១-២២ ថា ...កាលណាមានព្យាង្គពីរ ហើយព្យាង្គដើមមានសព្ទជាអឃោសៈ ឬជាឃោសៈ ព្យាង្គខាងចុងក៏រនសំឡេងទៅតាមព្យាង្គដើម មិនបាច់ថែមវណ្ណយុត្តិឡើយ ដូចពាក្យ ÷ សង្វាត... ប្រវែង... ទាហាន...។ តួព្យញ្ជនៈផ្សំ... ជើងអក្សរដែលយកទៅផ្សំរនសំឡេងទៅតាមតួលើ

តាមដោយសព្ទសំឡេងជា ឃោសៈ ឬអឃោសៈ មិនបាច់មានវណ្ណយុត្តិដូចជា ÷ ក្ល ខ្ល ក្ន ខ្ន... ស្ន ស្ម ក្រ ច្រ...។

ខ.លោក អៀវ កើស ក្នុងសៀវភៅ "ភាសាខ្មែរ" ទំព័រ១២-១៣០ បានណែនាំថា ព្យញ្ជនៈសំឡេងគ្រលរ ៨ អង្គ : ង ញ ន ម យ រ ល វ កាលបើជាអង្គប្រធានក្នុងព្យាង្គ ត្រូវប្រែសំឡេងទៅជាគ្រលួច នាកាលព្យញ្ជនៈដែលជាប្រធានក្នុងព្យាង្គជាមួយ ឬក្នុងព្យាង្គខាងមុខរបស់ពាក្យជាមួយនោះ មានសំឡេងគ្រលួច។

ព្យាង្គជាមួយ : ...ថ្ងារ ខ្ញុំ ស្នាម ថ្មី ខ្យល់...។

ព្យាង្គខាងមុខរបស់ពាក្យជាមួយ : សម្លាត់ កម្រាល បង្វិល...។

ព្យញ្ជនៈសំឡេងគ្រលួច... "ហ" កាលបើជាអង្គប្រធានក្នុងព្យាង្គ ត្រូវប្រែសំឡេងទៅជាគ្រលរ "ហ៊" នាពេលព្យញ្ជនៈជាប្រធានក្នុងព្យាង្គខាងមុខរបស់ពាក្យជាមួយនោះ មានសំឡេងគ្រលរ : ជំហរ ព្រហាម ទាហាន...។

គ.ក្នុងសៀវភៅ "មូលវិជ្ជា ខេមរភាសា" ភាគ១ ទំព័រ១១០ មានសេចក្ដីថា កាលណាមានសព្ទព្យាង្គដើម ឬសព្ទតួអក្សរដើមបង្ហោនមក អក្សរសម្លាប់តួនៃព្យាង្គទី២ ឬអក្សរសម្លាប់តួទី២ មិនចាំបាច់ដាក់មូសិកទន្ត ឬត្រីសព្ទឡើយ ដូចពាក្យប្រមោយ ទាហាន សាលា ជីវ ព្រហើន...។ ទំព័រ១២៤ មានសេចក្ដីថា ...ត្រូវចាំថា មានព្យញ្ជនៈមួយពួកសម្លីលំអោនបានទៅពីរយ៉ាង គឺពួក ង ញ ន ម យ រ ល វ ពួកនេះបើយកទៅផ្ញើនឹងពួកព្យញ្ជនៈណាមួយ សម្លីក៏ដូលទៅតាម ព្យញ្ជនៈនោះ ឧបមាដូចជា "ន" ផ្ញើទៅនឹង "ខ" បានទៅជា "ខ្ន"។

ឃ.ក្នុងសៀវភៅ "វចនានុក្រមខ្មែរ" ពុទ្ធសាសនបណ្ឌិត្យភាគ១ ទំព័រ១ មានសេចក្ដីថា អក្សរឃោសៈនៅពីខាងដើម "ហ" កុំបាច់ប្រើត្រីសព្ទ ( ៊ ) ឱ្យជា "ហ៊" ដូចជា ជំហាម ជំហរ ទាហាន...។ អក្សរអឃោសៈនៅពីខាងដើម ឬពីខាងលើអក្សរដែលត្រូវសម្លាប់ ទើបមានសំឡេងតូច គឺ ង ញ ន ម យ រ ល វ មិនត្រូវសម្លាប់ដោយមូសិកទន្ត ( ៉ ) នេះទេ ដូចជា កិរិយា ចរិយា សម្លេង ខ្នាត ក្មេង...។

ង.លោកសាស្ត្រាចារ្យ កេង វ៉ាន់សាក់ ក្នុងសៀវភៅ "មូលភាពនៃការបង្កើតពាក្យថ្មី" ឆ្នាំ១៩៦៤ ទំព័រ ៥០៨-៥០៩ បានពន្យល់ថា នៅក្នុងព្យញ្ជនៈសំយោគ ដែលជាព្យញ្ជនៈនិស្ស័យមួយបែប ស្រៈ គឺជាស្រៈរបស់ព្យញ្ជនៈផ្ញើជើង ប៉ុន្តែក្នុងករណីដែលព្យញ្ជនៈត្រួតលើជាព្យញ្ជនៈក្នុងវគ្គ ឬ "ស" ហើយព្យញ្ជនៈផ្ញើជើងជាពួកចុងវគ្គ ឬពួកសេសវគ្គ យ រ ល វ ក្នុងករណីនោះ ព្យញ្ជនៈត្រួតលើអាចផ្ដល់សំឡេង អ ឬអ៊ិ របស់ខ្លួនទៅលើព្យញ្ជនៈផ្ញើជើង : ខ្ន ថ្ក ខ្ង ស្ង...។

នៅក្នុងពាក្យរៀងព្យាង្គ ឬព្យាង្គតំរួត ព្យាង្គដើមណាដែលកើតមកអំពីព្យញ្ជនៈក្នុងវគ្គ ឬ "ស" ព្យាង្គដើមនោះ អាចផ្ដល់សំឡេង អ ឬអ៊ិ របស់ខ្លួនទៅលើព្យាង្គបន្ទាប់ ដែលកើតអំពីព្យញ្ជនៈចុងវគ្គ ឬសេសវគ្គ យ រ ល វ ហ។

ឧទាហរណ៍ : ស្រមោច ( ស្រម៉ោច) កម្ចាច ( កម្ចាំច) ព្រហាម ( ព្រហ៊ាម)...។

ប៉ុន្តែប្រសិនបើព្យាង្គបន្ទាប់កើតដោយខ្យល់ក្នុងវគ្គវិញនោះ ព្យាង្គដើមពុំអាចមានឥទ្ធិពលមកលើបានឡើយ ។ឧទាហរណ៍: ពូកែ ក្រទា បន្ទាប់...។

ការរៀបរាប់ខាងលើបង្ហាញឱ្យឃើញថា ÷

- ក្បួនអក្ខរាវិរុទ្ធ "ឥទ្ធិពលមូលភេទ ឬទំនាញសូរ" មានតាំងពីយូរមកហើយ
- សញ្ញាព្យញ្ជនៈដែលអាចទទួលឥទ្ធិពលមូលភេទពីគេ គឺ ង ញ ន ម យ រ ល វ និង ហ
- សញ្ញាព្យញ្ជនៈដែលមានឥទ្ធិពលមូលភេទលើគេគឺ សញ្ញាព្យញ្ជនៈដើមវគ្គ និងក្នុងវគ្គ ព្រមទាំងសញ្ញាព្យញ្ជនៈក្នុងសេសវគ្គ "ស និងអ"។ ( នៅមានត)

លោក សួ មុយឃៀង

# ភាសា

## កុំច្រឡំ

### <u>កំពង់_កំពុង និង_នឹង ហ្នឹង_នុង</u>

**ក_កំពង់**

១-កំពង់ ន. : ទីកន្លែងនៅមាត់ទឹកដែលជនានុជនចុះឡើង ឬចតទូក កប៉ាល់ជាដើម ។

ឧ. កំពង់ទូក កំពង់កប៉ាល់ កំពង់ទឹក កំពង់ផែ ។

២-កំពង់ ន. : ឈ្មោះទីកន្លែង ។

ឧ.កំពង់ចាម កំពង់ធំ កំពង់ត្រឡាច កំពង់លែង កំពង់សៀម កំពង់ស្វាយ ។

**ខ_កំពុង**

១-កំពុង គុ. : ដែលពេញកំពូកកណ្ដាលឡើងមិនរាបស្មើ ។

ឧ. ពេញកំពុង ថ្កាល់កំពុង ។

២-កំពុង និ. : កាលក្នុង កាលដែលជាប់នៅក្នុងរវាង ។

ឧ.កំពុងធ្វើការ កំពុងលេង កំពុងរវល់ ។

**គ_និង**

១-និង និ. : ទាំង ព្រមទាំង ផង នេះផង នុះផង ។

ឧ.អ្នក និងខ្ញុំ គោនិងក្របី សុខ និងទុក្ខ ហើយនិង ។

**ឃ_នឹង**

១-នឹង កិ.នុ. : មុខជា ប្រាកដជា គង់ គង់តែ ( ប្រាប់អនាគតកាល) ។

ឧ. ចាំថ្ងៃស្អែកខ្ញុំនឹងទៅផ្ទះអ្នក ។ យើងគង់តែនឹងបានជួបគ្នាទៀត ។ ការនេះមុខជានឹងហើយមិនខាន ។ សន្តិភាពប្រាកដជានឹងកើតមាននៅពេលខាងមុខ ។

២-នឹង គុ. : ស្ងៀម ជើយ មិនកម្រើក មិនប្រែប្រួល ។

ឧ. ទឹកនឹង ភ្លៀងនឹង កម្ដៅនឹង កម្រិតនឹង ទំហំនឹង ជម្ងឺនឹង ។

៣-នឹង កិ.វិ. : ស្ងៀម ជើយ មិនកម្រើក មិនប្រែប្រួល ។

ឧ.អង្គុយនឹងថ្កល់ រត់នឹងល្អ ឈរឱ្យនឹង កាន់ឱ្យនឹង ដៃ ។

៤-នឹង អា.និ. :

- ដោយ ឧ.ដួសសម្លនឹងវែក ដាំបាយនឹងឆ្នាំង កាប់ឈើនឹងពូថៅ ទប់ខ្លួននឹងឈើច្រត់ ។

- ជាមួយ ដោយសារ ។ ឧ.ទៅនឹងខ្ញុំ នៅនឹងគេ ស៊ីនឹងគេ រស់ជាមួយនឹងគេ ។
- ឮដំ នៅត្រង់ ។ ឧ.ព្យួរអាវនឹងដៃកែវ បោះដែកគោលនឹងជញ្ជាំង ។

៥-នឹងធឹង : ដែលមានឫកពាររម្យទមមិនឆ្គង ។

៦-នឹងន : នឹងធឹង ។

៧-នឹងនួន : នឹងធឹងសមរម្យមិនឆ្គង ។

## ខ~ហ្នឹង

១-ហ្នឹង វិ.ស. : នុះ ។ ឧ.ហ្នឹងហើយ ហ្នឹងឯង ដំណើរហ្នឹង ។

២-ហ្នឹង និ. : ដូច្នឹង អ៊ីចឹង អើ (ពាក្យសាមញ្ញ) ។

ឧ. (អ្នកម្នាក់ប្រាប់ថា) ទៅកុំខានហ្ន៎ះ (អ្នកម្នាក់ឆ្លើយតប ថា) ហ្នឹង! ។

- ហ្នឹងហើយ! ហ្នឹងឯង! យ៉ាងហ្នឹង! ដូចហ្នឹង! ហេតុហ្នឹង! ។
- ហ្នឹងហើយ! ហ្នឹងឯង! (សម្រាប់សំឡេងខ្ពស់ស្រួចខ្លាំង) ។

## ច~នុំង

នុំង សព្វ. : នុំះ ហ្នឹង (ពាក្យសាមញ្ញ) ។ ឧ.នាងនុំង មនុស្សនុំង យ៉ាងម៉េចទៅរឿងនុំង? ។

លោក ចែម ផាន

មន្ត្រីខុទ្ទកាល័យឯ.ឧ ទេសរដ្ឋមន្ត្រី-

រដ្ឋមន្ត្រីក្រសួងអ.យ.ក.

| | |
|---|---|
| មើលសត្វកណ្ដៀរកពូនដី | មើលសត្វបក្សីក្រងសម្បុក |
| មើលឃ្មុំជាដើមសាងក្ដីសុខ | ព្យាយាមសម្រុកបានសម្រេច។ |
| ទឹកស្រក់តក់ៗទម្លុះថ្ម | រលកគៗថ្មសឹកដាច់ |
| កាន់ការងារអ្វីត្រូវប្ដូរផ្ដាច់ | ផលល្អសម្រេចព្រោះព្យាយាម។ |
| | បទពិចារណា |

# គណិតវិទ្យា

## ការដោះស្រាយចំណោទ (ត)

II- **ការដោះស្រាយចំណោទ**

**ក. លំនាំនៃការដោះស្រាយចំណោទ**

ចំណោទគឺជាមជ្ឈមណ្ឌលនៃសកម្មភាពគណិតវិទ្យា ជាផ្នែកមួយដ៏សំខាន់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងជាមុខវិជ្ជាដែលគេយកមកប្រើប្រាស់តាមផ្ទះ នៅក្នុងសហគមន៍ នៅកន្លែងធ្វើការ...។ បង្រៀនសិស្សឱ្យចេះរកដំណោះស្រាយចំណោទ គឺដាក់សិស្សឱ្យស្ថិតក្នុងស្ថានភាពស្រាវជ្រាវយ៉ាងសកម្ម ធ្វើយ៉ាងណាឱ្យគេទទួលបាន និងកសាងសញ្ញាណថ្មីៗ ចំណេះដឹងគណិតវិទ្យា ព្រមទាំងចេះត្រួតពិនិត្យ និងវាយតម្លៃចំណេះដឹងដែលទទួលបានទាំងនោះផង។

- ការងារសំខាន់ដំបូងបង្អស់សម្រាប់ការដោះស្រាយចំណោទ គឺជាសកម្មភាពអានទាំងស្រុង អានដើម្បី :
  - **ស្វែងយល់អត្ថន័យរបស់ចំណោទទាំងមូល** ( ស្រមៃ និងបង្ហាញពីដំណើររឿងក្នុងអត្ថបទចំណោទ) ។
  - **ស្រង់ រក និងរៀបចំព័ត៌មាន** ដែលមានក្នុងអត្ថបទចំណោទ។
  - **ជ្រើសរើសព័ត៌មាន** (កំណត់ប្រភេទចំណោទ បកស្រាយព័ត៌មានដោយផ្ដើមចេញពីសំណួមពរ ឬសំណួរ) ។

អត្ថបទចំណោទត្រូវមានរចនាបថឆ្លើយតបទៅនឹងសមត្ថភាពគណិតវិទ្យាដែលត្រូវអភិវឌ្ឍ។ ជួយសិស្សឱ្យចេះអានអត្ថបទចំណោទ ក៏ដូចជាបានជួយសិស្សក្នុងការអានអត្ថបទទូទៅ ឬក្នុងការរៀនភាសា។ ដូចនេះ អត្ថបទចំណោទត្រូវមានភាពសំបូរបែបទាំងវាក្យស័ព្ទ វាក្យសម្ព័ន្ធ និងទម្រង់។ ប្រធានចំណោទមិនគួរជានិច្ចកាលជាអត្ថបទសុទ្ធសាធនោះទេ គួរតែបង្ហាញជាគំនូសតាង ឬជាតារាងផ្សេងៗ ដើម្បីហ្វឹកហាត់សិស្សក្នុងការស្វែងយល់បម្រាប់ដែលមានប្រភេទប្លែកៗគ្នា ( ឧទាហរណ៍ ចំណោទផ្សេងៗនឹងបង្ហាញជូននៅលេខបន្ទាប់) ។

- សកម្មភាពដែលត្រូវធ្វើជាប្រចាំមួយទៀត គឺជួយសិស្សឱ្យ**និយាយពីប្រធានចំណោទឡើងវិញ** (មិនមែនអានប្រធានចំណោទឡើងវិញទេ) ។ នៅពេលសិស្សរកនឹកនិយាយដោយប្រើប្រាស់ពាក្យសម្ដីផ្ទាល់របស់គេ គឺជាឱកាសដែលធ្វើឱ្យសិស្សបានចូលស៊ុបនៅក្នុងស្ថានភាពចំណោទ ហើយម្យ៉ាងទៀតក៏ជាឱកាសដែលគ្រូអាចត្រួតពិនិត្យការយល់ដឹងរបស់សិស្សផង។
- ចំណុចសំខាន់បន្ទាប់ គឺឈានទៅសរសេរសេចក្ដីសង្ខេបនៃចំណោទ។ ការងារនេះជាជំហានមួយក្នុងការជួយជំរុញសិស្សឱ្យកាន់តែយល់ប្រធានចំណោទបានកាន់តែច្បាស់ថែមទៀតបន្ទាប់ពីបាននិយាយរួចមក។ ការផ្លាស់ប្ដូរពីការងារផ្ទាល់មាត់ទៅជាការងារសរសេរ ឬសំណេរមានប្រយោជន៍យ៉ាង

ច្រើន សម្រាប់សិស្សក្នុងការវិភាគចំណុចលំអិតដែលមាននៅក្នុងប្រធានចំណោទ។

- ចេះដោះស្រាយចំណោទ គឺចេះសួរខ្លួនឯង និងចេះចោទសួរ :
  - ចេះសួរខ្លួនឯង មានន័យថា សួរអំពីប្រភេទផ្សេងៗនៃបម្រាប់ដែលមាននៅក្នុងស្ថានភាពចំណោទ ពោលគឺស្រាវជ្រាវរកច្រកចេញ មានចម្ងល់ថា បើមានបម្រាប់ប៉ុណ្ណេះ តើត្រូវដោះស្រាយតាមផ្លូវណា? ប្រើប្រមាណវិធីអ្វីខ្លះ?
  - ចេះចោទសួរ គឺបន្ថែមការស្រាវជ្រាវមួយកម្រិតទៀត ពោលគឺក្រៅពីសំណួរដែលមានក្នុងប្រធានចំណោទ ឬចំណោទខ្លះដែលខ្វះសំណួរ តើគេអាចចោទសួរបែបនេះ ឬសំណួរផ្សេងពីនេះបានដែរឬទេ?

**តើអាចមានប្រយោជន៍អ្វីខ្លះដល់សិស្ស ប្រសិនបើគេឱ្យសិស្សដោះស្រាយចំណោទខ្លះដែលមានសំណួរមិនគ្រប់គ្រាន់ ឬគ្មានសំណួរ?**

ក្នុងករណីនេះ សិស្សអាចនឹងស្ថិតនៅក្នុងស្ថានភាពបញ្ហាមួយថ្មីទៀត ក្រៅពីការដោះស្រាយរកចម្លើយដែលសិស្សធ្លាប់បានជួបប្រទះកន្លងមក។ ស្ថានភាពថ្មីនេះ អាចនឹងបង្កលក្ខណៈឱ្យសិស្សចេះធ្វើការងារស្រាវជ្រាវអំពីទម្រង់ផ្សេងៗជាច្រើនរបស់ចំណោទ និងចេះរុករកបញ្ហារបស់ចំណោទ ហើយនិងចេះតាក់តែងសំណួរដែលសមស្រប ឬដែលទាក់ទងទៅនឹងការដោះស្រាយរកចម្លើយ។ ជាការពិត ប្រសិនបើលោកគ្រូ អ្នកគ្រូ អាចបន្ថែមប្រធានចំណោទប្រភេទថ្មីនេះ សិស្សមុខជាបង្កើនការអានប្រធានដោយយកចិត្តទុកដាក់មួយកម្រិតទៀត។ ដូចនេះ អ្នកគ្រូ លោកគ្រូ គួរសាកល្បងដើម្បីប្រសិទ្ធភាពនៃការរៀន និងបង្រៀន។

(នៅមានត)

**លោកស្រី ម៉ិន សារ៉ែន**

---

## បទកាកគតិ

**(បែបជាប់ទង)**

**របរជាតិខ្មែរ ខ្មែរយើងគួរតែ តែជួយទិញគ្នា**
**គ្នាលក់មិនទិញ ទិញឯគេជា ជាជាតិខុសគ្នា**
**គ្នាយើងធ្លាក់ក្រ។**

**ក្រសេដ្ឋកិច្ច កិច្ចក្នុងស្រុកតិច តិចមិនជាប់ត**
**តទៅថ្ងៃមុខ មុខគ្មានបានល្អ ល្អម្តេចបើក្រ**
**ក្រទាំងនគរ។**

អៀង សាយ

# គណិតវិទ្យា

## ចំណោទ

- ថ្នាក់ទី ៤
- មេរៀនទី ២ : វិធីបូក និងដក
- សៀវភៅសិស្សទំព័រ ១២
- សៀវភៅគ្រូទំព័រទី ២៨

**អត្ថបទជំនួយ**

នៅក្នុងរាត្រីស្រមោសររបស់សាលារៀនមួយ មានសិស្សចុះឈ្មោះដូចតទៅ ÷

- ថ្នាក់ទី ៣ បានមកចុះឈ្មោះចំនួន ៤៨នាក់
- ថ្នាក់ទី ១ បានមកចុះឈ្មោះ១០នាក់តិចជាងថ្នាក់ទី ៣
- ថ្នាក់ទី ៥ មានចំនួនស្មើសិស្សថ្នាក់ទី ៣
- ថ្នាក់ទី២ មានចំនួនសិស្ស ៦នាក់ច្រើនជាងថ្នាក់ទី ១
- ថ្នាក់ទី ៤ មានចំនួនសិស្ស ៥០នាក់ ។

តើចំនួនសិស្សមកចុះឈ្មោះមានប៉ុន្មាននាក់ ÷

- សម្រាប់ថ្នាក់ទី ១?
- សម្រាប់ថ្នាក់ទី ២?
- សម្រាប់ថ្នាក់ទី ៣?
- សម្រាប់ថ្នាក់ទី ៤?
- សម្រាប់ថ្នាក់ទី ៥?

**ចម្លើយ :**

- សិស្សថ្នាក់ទី ១ បានមកចុះឈ្មោះចំនួន ៣៨នាក់
- សិស្សថ្នាក់ទី ២ បានមកចុះឈ្មោះចំនួន ៤៤នាក់
- សិស្សថ្នាក់ទី ៣ បានមកចុះឈ្មោះចំនួន ៤៨នាក់
- សិស្សថ្នាក់ទី ៤ បានមកចុះឈ្មោះចំនួន ៥០នាក់
- សិស្សថ្នាក់ទី ៥ បានមកចុះឈ្មោះចំនួន ៤៨នាក់ ៕

ដកស្រង់ : លោក កែច យ៉ារ

# គំនូរ

## វិធីបង្រៀនគំនូរ (ត)

### បក្សីស្រុក (គំនូរស្លាបប៉ាកកា)

គំនូរវាសក្នុងទំព័រនេះមានសភាពលំបាកបន្តិច ។ ត្រូវពិនិត្យឱ្យបានជាក់លាក់មុននឹងគូរគំនូរមាន់ដែលគូរបង្ហាញនូវដើមទំព័រនេះ ( មាន់ឈ្មោល-ញី) យើងត្រូវវិភាគនូវរាងរៅសត្វនេះជាដំបូងសិន ។ សត្វបក្សីកើតមកអំពីស៊ុត (រូបទី១) ដូចនេះដើម្បីគូររូបមាន់នេះត្រូវចាប់គូរស៊ុតជាមុនដែលជារាងរៅខ្លួន ។ ត្រូវកត់ចំណាំថា ពងមាន់ ពងទា និងពងក្ងានមានរាងរៅខុសគ្នា ពងក្ងានរាងមូលខ្លី ឯពងទារាងមូលទ្រវែង ។ ដូចនេះ ដើម្បីគូរសត្វបក្សីទាំងនេះ គេត្រូវគូរស៊ុតដែលជារាងខ្លួនជាមុន ទើបបណ្តុះ ក និងក្បាល ជើង និងកន្ទុយជាក្រោយ ។

**មាន់ឈ្មោល-ញី**

(គំនូរស្លាបប៉ាកកា)




ក-មាន់ឈ្មោល ខ-របៀបគូរមាន់ឈ្មោលជាវគ្គ គ-មាន់ញី

ឃ-របៀបគូរមាន់ញីជាវគ្គ ង-គំនូរសម្រួល ច-គំនូរតុបតែងលំអ

## ទា_ក្ងាន (គំនូរស្វាបចាំកកា)



ក_ទា ខ_របៀបគូរទាជាវគ្គ គ_ក្ងាន

ឃ_របៀបគូរក្ងានជាវគ្គ ង_គំនូរសម្រួល

## បក្សីក្រៀល



**<u>បក្សីទូទៅ</u>**

ក-ល្វាចេក : ត្រូវកត់សម្គាល់លើបណ្ដោយកន្ទុយ និងស្នាមប្រឡាក់ជាដុំៗនៅលើខ្លួន ។

ខ-របៀបគូរសត្វល្វាចេកចែកជាវគ្គ ។

គ-គំនូរវាសនៃបក្សីខ្លះ : ពីស្ដាំទៅឆ្វេង : ពពិច ល្វាចេក សារិកាកែវ ចាបស្រុក និងព្រាប ។ ត្រូវកត់សម្គាល់ថា ការប្លែកគ្នានៃទំហំខ្លួនរបស់បក្សីទាំងនេះ មានរង្វង់មូល ឬមូលទ្រវែងជាការសម្គាល់ ។

ឃ-ក្រសាហើរ (គំនូរតុបតែងលំអ) ។

**<u>មំសាហារបក្សី</u>** (គំនូរស្ទាបចាប់កកា)




ក-គំនូរវាសសត្វអាត ខ-របៀបគូរអាតជាវគ្គ គ-ទីទុយ

ឃ-របៀបគូរទីទុយជាវគ្គ ង-ក្បាលពួកមំសាហារសត្វ ។

(នៅមានត)

លោក ផ៉ាន់ ត្រា




# ប្រទេសកម្ពុជាពី គ.ស.១៨៥០ (តទៅ)

បទពាក្យ ៧

## ព្រះបាទសម្ដេចស៊ីសុវត្ថិមុនីវង្ស "១៩២៧-១៩៤១"

ព្រះបាទសម្ដេចស៊ីសុវត្ថិ ចូលទីវង្គតរវាងឆ្នាំ<br>
មួយពាន់ប្រាំបួនរយតាមចាំ ខាងចុងបន្ថែមម្ភៃប្រាំពីរ ។

ព្រះរាជបុត្រនៃព្រះអង្គ នាមព្រះមុនីវង្សអង្គភូមិ<br>
ស្នងរាជ្យបន្តផែនបបរី តាមប្រពៃណី រាជវង្ស ។

បារាំងតាបកេងខ្លាំងក្លាក្លាត់ ក្នុងរាជសម្បត្តិព្រះមុនីវង្ស<br>
បង្ខំតម្លើងក្រិតប្រាក់បង់ ពន្ធដារតាមប្លង់ទ្រព្យទាំងអស់ ។

ពន្ធគោ ពន្ធដីក្របីសេះ ពន្ធមនុស្ស ពន្ធផ្ទះ គ្មានចន្លោះ<br>
កម្រិតតម្លៃប្រាក់ពន្ធខ្ពស់ គួរឱ្យស្រណោះរាស្ត្រក្រក្រី ។

រកប្រាក់ពុំបានបង់ពន្ធដារ ថ្ងៃរះកាលណារត់ចូលព្រៃ<br>
គេចខ្លួនរត់ពួនព្រោះភិតភ័យ បារាំងចាប់វៃចងដាក់ខ្នោះ ។

ដាក់គុកបង្ខំរកប្រាក់បង់ ឱ្យគ្រប់បើចង់បានលែងដោះ<br>
ជាទុក្ខចំបែងឥតស្រាកស្រាន្ត ប្រជាទាំងអស់សែនវេទនា ។

ឯពួកបារាំងគេខិតខំ បង្កើតឱ្យធំក្រុមហ៊ុនវា<br>
អាជីវកម្មផ្នែកនានា ស្រូបយកផលាពីស្រុកយើង ។

ចម្ការកៅស៊ូ និងដីស្រែ បង្ខំរាស្ត្រខ្មែរធ្វើដូចភ្លើង<br>
ផលានុផលគេនាំឡើង កប៉ាល់ចេញវឹងប្រទេសក្រៅ ។

រហូតសព្វថ្ងៃដីណែលចាស់ ដីកន្លែងខ្លះជាប់ធ្លាប់ហៅ

ភូមិ-ស្រែបារាំងជាប់ជាមដៅ ទុកដល់កូនចៅជាប្រវត្តិ ។
សូមវង់ក្រចកបកសេចក្ដី ពិភពផែនដីញ័ររន្ធត់
ជួបសង្គ្រាមលោកសែនជូរចត់ អនុវត្តដោយលោកសេរី ។
ផ្ដើមដោយហ្វាស៊ីសអាល្លឺម៉ង់ ពួកគេប៉ុនប៉ងវាតទឹកដី
នៅលោកខាងលិចកើតភិតភ័យ ព្រឹត្តិការណ៍ថ្មីៗសែនធ្ងន់ធ្ងរ ។
នៅផ្នែកអាស៊ីពួកជប៉ុន រុករានជិះជាន់កើតវឹកវរ
ប្រទេសទន់ខ្សោយបាត់ជំហរ ពួកគេចូលមកក្ដាប់អំណាច ។
យោលតាមភាពខ្សោយនៃបារាំង ពេលនោះថៃឡង់ចិត្តកោងកាច
សាកល្បងពិនិត្យព្រំឥតខ្លាច សំឡុតបន្លាចឡាវកម្ពុជា ។
នៅថ្ងៃសាមសិបវិច្ឆិកា មួយពាន់ប្រាំបួនរយសែ វា
ធ្វើសកម្មភាពខាងយោធា វាយលុកពុះពារពង្រីកដែន ។
ជាតិថៃពួកខាងអែបអប ចុះចូលរណបក្នុងកំណែន
យោធាជប៉ុនខ្លាំងក្លាមែន ឱ្យកែព្រំដែនសាឡើងថ្មី ។
ប្រាំបួនខែប្រាំឆ្នាំសែមួយ ក្រុងតូក្យូជួយជាសាក្សី
ឱ្យមានការចុះហត្ថលេខី រវាងពួកថៃ និងបារាំង ។
សន្ធិសញ្ញានេះមានន័យ សន្តិភាពផុតភ័យផុតចម្បាំង
បែងចែកព្រំដែនធ្វើមឹងម៉ាំង បំពានយ៉ាងខ្លាំងដោយខុសច្បាប់ ។
ខាងជើងខ្សែស្របលេខដប់ប្រាំ ខេត្តខ្មែរតាមចាំដែលបានរាប់
ចំនួនបួនខេត្ត[១] ត្រូវគេភ្ជាប់ ដោយខុសទម្លាប់ឱ្យទៅថៃ ។
មជ្ឈដ្ឋានចក្រពត្តិនិយមថ្មី ឈ្លានពានទឹកដីឥតសំចៃ
ចូលឥណ្ឌូចិនរដ្ឋទាំងបី ប៉ុនប៉ងដាច់ថ្លៃត្រួតអាស៊ី[២] ។
ថ្ងៃម្ភៃប្រាំបួនខែកក្កដា ឆ្នាំសែមួយ វា ឧត្ដមនារី
បារាំងព្រមព្រៀងប្រគល់ទី ទឹកដីភូមិឱ្យជប៉ុន ។
ផលនៃកិច្ចព្រមព្រៀងពេលនេះ មានន័យពិសេសលើសមុនៗ
កងទ័ពបារាំងធ្លាក់ជាប់គុន ប្រគល់ជ័យភ័ណ្ឌខ្លះឱ្យគេ ។
គ្រានោះរាស្ត្រនៃកម្ពុជា រងទុក្ខវេទនាថែមឡើងទ្វេ
របបអំណាចត្រួតត្រាពីរ ជប៉ុនអាស៊ីបារាំងផង ។

(១) ខេត្តទាំងបួនមាន ក្រុងស៊ីសុផុន សៀមរាប កំពង់ធំ ស្ទឹងត្រែង
(២) គ្រប់គ្រងអាស៊ីអាគ្នេយ៍ ដើម្បីឈានក្ដាប់អាស៊ីទាំងមូល ។

ដំណាំកសិកម្មទាំងអស់ ខ្មែរប្រឹងកាប់គាស់ក្រៃកន្លង<br>
ឯផលជប៉ុនទិញវាសង តម្លៃសំណងថោកបំផុត ។<br>
សេដ្ឋកិច្ចពាណិជ្ជកសិកម្ម ខ្មែរយើងរាល់ឆ្នាំស្ទើររលត់<br>
ព្រោះពួកជប៉ុនបានហាមឃាត់ សម្រាប់ផ្គង់ផ្គត់ទាហានវា ។<br>
សង្គមខ្មែរមានជីវភាព អន់ថយដុនដាបវេទនា<br>
កើតឡើងដោយសារពួកយោធា ជប៉ុនពាលាវាជិះជាន់ ។<br>
ក្នុងឆ្នាំមួយពាន់ប្រាំបួនរយ សែមួយ សែប្រាំបីជំនាន់<br>
របបយោធាពួកជប៉ុន ជិះជាន់រាស្ត្រខ្មែរធ្លាក់ដុនដាប ។<br>
រាល់អំពើតាបកេងទាំងឡាយ ខ្មែរក្តៅក្រហាយជាដរាប<br>
នៅក្នុងសង្គមគ្រប់ស្រទាប់ ទើបជំរុញចាប់ផ្តើមតស៊ូ ។<br>
គ្រប់មជ្ឈដ្ឋានបញ្ញវន្ត ជំហរជាឈ្មាន់ឱ្យផ្លាស់ប្តូរ<br>
កំហឹងឈឺចាប់ជាតស៊ូ ជាតិរំភើបញ័រដោយបាតុកម្ម ។<br>
ស្របនឹងពិភពជ្រួលច្របល់ គ្រប់ជាតិសកលប្រាំមួយឆ្នាំ<br>
នៃសង្គ្រាមលោកភាគញីញ៉ាំ មនុស្សជាតិរងកម្មគ្រប់ពូជសាសន៍ ។<br>
ដោយខ្សែកនៅឯកម្ពុជា សែនរងខ្លោចផ្សាខ្លាំងក្លាណាស់<br>
អាណានិគមបានប្តូរផ្លាស់ ចាញ់ឈ្នះក្រឡះ ជប៉ុនបារាំង ។<br>
លុះដល់សែប្រាំចប់សង្គ្រាម ឈប់បង្ហូរឈាមនៅទូទាំង<br>
ពិភពលោកស្ងប់ផុតចម្បាំង បារាំងបន្តត្រួតត្រាខ្មែរ ។<br>
បិទវង់ក្រចកដកអត្ថន័យ វិលវៃរាប់ស្នាព្រះហស្តថៃ<br>
ព្រះបាទមុនីវង្សទ្រង់កែប្រែ សំណង់ថ្មីក្បែរក្រុងភ្នំពេញ ។<br>
ទីមួយគឺស្ពានព្រះមុនីវង្ស កោងខ្ពស់ស្រស់ខ្ទង់រហូតមិញ<br>
ឆ្លងកាត់បាសាក់តាមផ្លូវចេញ ធានីភ្នំពេញ ព្រៃនគរ ។<br>
ផ្លូវដែកភ្នំពេញបាត់ដំបង ដំណើរប្អូនបងស្រួលទៅមក<br>
ជិះដឹកចុះឡើងច្រើនឈ្នួរនរ មូលមីរអ៊ូអរសាទរក្រៃ ៕

លោក សោម ចាន់

គ្រូប.ថ.ស. ៧មករា ខេត្តស្វាយរៀង

# រណសិរ្សពីរធ្នូ

(បទពាក្យ ៧)

ព្រលឹងនៃខ្ញុំខ្មែរចងចាំ ទោះរយពាន់ឆ្នាំ ចាំមិនឃ្លាត
រណសិរ្សសាមគ្គីសង្គ្រោះជាតិ កម្ពុជាមូលញាតិជាតិបូរី ។
រណសិរ្សពីរធ្នូ បក្សប្រជា រះពីបូព៌ា ចិតប្រាំបី
កកើតកម្លាត់ ចោរអប្រិយ រំដោះទុក្ខភ័យជាតិខេមរា ។
កាលណោះប៉ុល ពត ចិត្តទុរយស ប្រាទខ្មែរចូលជ្រោះ គ្រោះមរណា
រីរក់ចាក់កាប់ ខ្មៅមោហា ឈាមដាបពសុធា ពាលពាសពេញ ។
ស្ទើរផុតរលត់ សូន្យទៅហើយ ឱខ្លួនខ្ញុំអើយ! ទុក្ខទោម្នេញ
រណសិរ្សមួយគត់ ជួយរសីវិញ ពាលខ្មៅខ្លាតចេញ នាំប្រាជ្ញប្រាយ ។
មហាសាមគ្គី នៃរណសិរ្ស រឹងមាំឥតទ្វេ ជ្រាបសព្វសាយ
ពូនមិត្តបរិសុទ្ធ រួមស្និទ្ធកាយ សាសន៍ជាតិជិតឆ្ងាយ ខ្លាំងក្លាពិត ។
វៀតណាម ឡាវ ជិតមិត្តរួមប្រាណ សន្តោសសន្តាន ប្ដូរជីវិត
ខ្ញុំខ្មែរទៅមុខ ជាក់រឹងឫទ្ធិ សម្រេចសម្រិត គ្រាណាត្រើយសុខ ។
ប្រាំពីរមករា ចិតប្រាំបួន រដ្ឋរៀបថៃថ្ងូន បក្សប្រមុខ
ប្រួលប្រែពីព្រៃ ចូលភូមិស្រុក រួមទុក្ខរួមសុខ ក្រុមសាមគ្គី ។
ដៃមួយលាងឈាម ជូតទឹកភ្នែក មួយទៀតពុនរែក ល្បាតភូមិទី
កាយាស្គមស្គាំង រោគញាំញី សាងរដ្ឋសោភី សង្គមថ្មី ។
សាធារណរដ្ឋប្រជាមា និតកម្ពុជា ស្មោះភក្ដី
រណសិរ្សវិវត្តន៍ យ៉ាងជាញជ័យ បានជាងឆ្នាំបី រីករូបរាង ។
ម្ដេពីរធ្នូ ឆ្នាំប៉ែតមួយ មាតាលើកស្ទួយ ឥតលំអៀង
មហាសន្និបាតគិតប្រិតប្រៀង ទីបី ស្ថិតស្អាង នាមឧត្ដម ។
ចារឈ្មោះរណសិរ្សសាមគ្គី កសាងការពារមាតុភូមិ
រដ្ឋប្រែប្រឹងប្រែង សាងសង្គម ឈានឆ្ពោះយសថ្កុំរដ្ឋកម្ពុជា ។
មាតារួបរួម ជះសាចផ្សាយ ដាស់ខ្មែរគ្រប់កាយ ពួតដៃគ្នា
ផ្សះផ្សាឈាមសាច់ គ្មានពានពារ ជនខ្មែរកម្ពុជា ល្អត្រឹមត្រង់ ។

លយលឿនចរចូល ឆ្នាំកៅបី    ស្ទួយរាជ្យវិលវៃ រះត្រចង់
រាជាណាចក្រដែលបាត់បង់    ប្រឹងប្រិតផ្ចិតផ្ចង់ ចិត្តស្មោះសរ។
រាជាណាចក្រកម្ពុជា    រាជរដ្ឋមាតា(១) ដ៏បវរ
មាតាឈ្មោះឈ្មោះខ្មែរត្រេកអរ    ខៀវ ក្រហម ស រលុបបាត់។
មាតាឈ្មោះឈ្មោះ! ភ្លឺភពផែន    សម្ដេចហ៊ុន សែន បានចែងចាត់
កំពូលប្រាជ្ញល្បី ល្បីមិនស្ងាត់    សកលចារចាត់រដ្ឋបុរស។
ឥឡូវរណសិរ្សវឌ្ឍនាការ    ជ័យជោគអស្ចារ្យ រដ្ឋលូតលាស់
ប្រារព្ធនាមថ្មី ប្រពៃយស    អភិវឌ្ឍន៍ខ្ពស់ ជាគោលការណ៍។
រណសិរ្សសាមគ្គីអភិវឌ្ឍន៍    មាតុភូមិប្រាកដ ខែមេសា
ពីរពាន់ប្រាំមួយ ថ្ងៃមហា(២)    សន្និបាតចែងចារ លើកទីប្រាំ។
ឆ្នាំនេះពីរធ្នូ ពីរពាន់ប្រាំពីរ    ជាតិជនមូលមីរ មូលសកម្ម
ជិតបីទសវត្សរ៍ ខ្ញុំជាក់ចាំ    ខ្ញុំខ្មែរទូទាំង សាទរក្រៃ ៕

**លោក ឆេង តែល**

**អនុប្រធានគាវិ.ស.យ.ក. ខេត្តកំពង់ឆ្នាំង**

## ការឱ្យអភ័យ ជាគុណធម៌ដ៏សំខាន់សម្រាប់មនុស្ស

មានមនុស្សចំនួនច្រើន នៅពេលធ្វើទានរមែងនឹកដល់វត្ថុទាន គឺឱ្យរបស់របរផ្សេងៗដែលជាទាន នោះឯង។ បើនឹងឱ្យច្រើន ក៏ត្រូវត្រៀមរបស់ឱ្យច្រើន ហើយការខៀយហត់ក៏មានច្រើនដែរ។ របៀបនេះ គេចេះត្រេកអរនឹងធ្វើទៅបាន ប៉ុន្តែបើមានអ្នកណាម្នាក់មកប្រព្រឹត្តអ្វីឱ្យថ្នាំថ្នងលើគេនោះ គេមិនចេះ ឱ្យអភ័យក្នុងការភ្ញាំងភ្ញាត់ ប្រព្រឹត្តថ្នាំថ្នងរបស់អ្នកដទៃនោះឡើយ។

តាមពិតមនុស្សយើង គួរហ្វឹកហាត់ឱ្យនូវអភ័យ ព្រោះនេះគឺជាទានម៉្យាងដែលអាចឱ្យអ្នកដទៃ មិន មានភ័យទៅបាន ហើយខ្លួនឯងក៏បានសប្បាយចិត្តផងដែរ។ ការហ្វឹកហាត់យ៉ាងនេះ នឹងអាចបានទៅជា ទេវតាក្នុងមនុស្សលោក។

គប្បីជ្រាបថា "ការធ្វើខុស គឺជារឿងរបស់មនុស្ស ឯការឱ្យអភ័យវិញនោះ គឺជារឿងរបស់ ទេវតា" ដោយសេចក្ដីថា មនុស្សធម្មតារមែងមានការធ្វើខុស ចំណែកឯមនុស្សចិត្តខ្ពស់វិញនោះ រមែង ចេះឱ្យនូវអភ័យ មិនសន្សំរឿងបន្តិចបន្តួចឡើយ។

សុខចិត្ត និងគុណភាពនៃជីវិត

(១) រាជរដ្ឋមាតា : មាតារាជរដ្ឋាភិបាល។

(២) ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៦ មហាសន្និបាតរណសិរ្សលើកទី៥ កំណត់នាមថា "រណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា



## ល្បែងបំពេញលេខស៊ូដូគុ (SUDOKU)

ស៊ូដូគុ ជាភាសាជប៉ុន មានន័យថា លេខទោល ជាពាក្យបំព្រួញនៃឃ្លា Suuji Wa Dokushin Ni Karigu បកប្រែថា លេខទាំងឡាយត្រូវមាន (ឬប្រើ) តែម្តងគត់។

**ប្រវត្តិស៊ូដូគុ** (SUDOKU)

ដំបូងឡើយ គឺលោក Leonhard Euler គណិតវិទូស្វីស ដែលបានដកស្រង់គំនិតពីគណិតវិទ្យានៃសម័យយុគកណ្តាលឈ្មោះថា "ការេឡាទីន" មករៀបចំជា "កន្លែងចុះលេខ" នៅរវាងឆ្នាំ១៧០០។ "កន្លែងចុះលេខ" ពុំសូវទទួលបានប្រជាប្រិយភាពទេ។ ក្រោយមក នៅឆ្នាំ១៩៨៤ ល្បែង "កន្លែងចុះលេខ" នេះបានចូលមកដល់ទឹកដីជប៉ុន ហើយទទួលបានជោគជ័យយ៉ាងឆាប់រហ័ស។ លោក Nobuhiko Kanamoto បានបោះពុម្ពផ្សព្វផ្សាយ ល្បែងបំពេញលេខ SUDOKU ដូចន័យខាងលើនេះ ក្នុងទស្សនាវដ្តីល្បែងផ្សេងៗរបស់ជប៉ុនឈ្មោះ Nikoli។

នៅឆ្នាំ១៩៩៧ មានជនជាតិញ៉ូវហ្សេឡង់ម្នាក់ឈ្មោះ Wayne Gould បានប្រទះឃើញល្បែងនេះនៅពេលដែលគាត់ធ្វើដំណើរទៅជប៉ុន ក៏បាននាំ SUDOKU ចូលទៅសហរដ្ឋអាមេរិក។ គាត់បានរៀបចំជាកម្មវិធីកុំព្យូទ័រអស់ពេលរាប់ឆ្នាំ ដើម្បីឱ្យគេប្រើប្រាស់នៅអាមេរិក។

បច្ចុប្បន្ននេះ SUDOKU កំពុងពេញនិយមនៅលើពិភពលោក។ SUDOKU មានចុះផ្សាយនៅតាមសារព័ត៌មាននានាចំនួនជាង១៤០ ពាសពេញពិភពលោក និងតាមវិបសាយជាច្រើន។ នៅប្រទេសយើងកាសែតកំបូជស័រក៏មានចុះ SUDOKU ដែរ។

**លក្ខណៈស៊ូដូគុ**

ដូចអត្ថន័យខាងលើ ស៊ូដូគុ គឺត្រូវប្រើលេខទាំងឡាយតែម្តងគត់ ដែលគេអាចបែងចែកបានជាច្រើនកម្រិត។ កម្រិតងាយបំផុត គឺការេបួនថតដែលជាការេមួយចែកជា៤ថត ថតនីមួយៗមានការេតូចៗ ៤ ដោយប្រើលេខបួនតួ (១, ២, ៣, ៤) ឬអក្សរ៤តួ (A, B, C, D) ឬរូបភាព ៤ខុសៗគ្នា (△□○★) សម្រាប់បំពេញ។

លក្ខខណ្ឌតែមួយគត់ គឺតាមការេជួរដេក ការេជួរឈរ និងការេក្នុងថតនីមួយៗ កុំឱ្យមានរូប អក្សរ ឬលេខ

ស្ទួនគ្នា។

<u>ឧទាហរណ៍</u>: ចូរប្រើប្រាស់សញ្ញាសម្គាល់ទាំង ៤ នេះ △□○★ ដើម្បីគូរបំពេញក្នុងតារាងខាងក្រោម :

| | | | |
|---|---|---|---|
| | △ | □ | |
| □ | | | △ |
| ★ | | | □ |
| | □ | ★ | |

→

**ចម្លើយ**

| | | | |
|---|---|---|---|
| ○ | △ | □ | ★ |
| □ | ★ | ○ | △ |
| ★ | ○ | △ | □ |
| △ | □ | ★ | ○ |

ចូរប្រើប្រាស់លេខ ១ ២ ៣ ៤ សរសេរបំពេញក្នុងតារាង :

| | | | |
|---|---|---|---|
| | | ២ | |
| ១ | ២ | ៣ | |
| | ៤ | ១ | ២ |
| | ១ | | |

→

**ចម្លើយ**

| | | | |
|---|---|---|---|
| ៤ | ៣ | ២ | ១ |
| ១ | ២ | ៣ | ៤ |
| ៣ | ៤ | ១ | ២ |
| ២ | ១ | ៤ | ៣ |

ដើម្បីឱ្យមានភាពលំបាកជាងនេះបន្តិច គេឱ្យលេខ អក្សរ ឬរូបកាន់តែតិចទៅដូចជា :

| | | | |
|---|---|---|---|
| | | | |
| ២ | | ១ | |
| | ៤ | ៣ | |
| | | | |

| | | | |
|---|---|---|---|
| | D | | |
| | | D | |
| | | A | |
| | C | | |

កម្រិតខ្ពស់ជាងទៀត គឺការេ៦ថត ការេ៩ថត ការេ១៦ថត ការេ២៥ថត...។ ប៉ុន្តែជាទូទៅគេច្រើនលេងការេ ៩ថត។

**ការេ ៦ថត**

| | | | | | |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

## ការេ ៩ចត

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ៩ | ២ | | | ៤ | ៧ | | |
| ១ | ៥ | | | ៦ | | ២ | | ៨ |
| | | | | ១ | ២ | | ៤ | ៩ |
| | | | | ៥ | ៨ | ៦ | | |
| ៨ | ៤ | | | ៣ | | | ៥ | ២ |
| | | ៣ | ២ | ៩ | | | | |
| ៦ | ១ | | ៨ | ៤ | | | | |
| ២ | | ៥ | | ៧ | | | ៦ | ១ |
| | | ៧ | ៦ | | | ៨ | ៩ | |

## ការេ ១៦ចត

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |

## គុណប្រយោជន៍

ល្បែងបំពេញលេខស៊ូដូគុអាចជួយឱ្យយើង ៖

- មានភាពរហ័សរហួនក្នុងការប្រើក្រសែភ្នែក
- មានជំនាញក្នុងការវិភាគបែបតក្កវិជ្ជា
- បង្កើនការចងចាំបានល្អ ។

លោកគ្រូ អ្នកគ្រូ អាចរៀបចំល្បែងស៊ូដូគុសម្រាប់សិស្សលេងនៅគ្រប់កម្រិតសិក្សា តាំងពីមត្តេយ្យ បឋម

មធ្យម... បាន។ ពេលសិស្សបានស្គាល់ និងចេះលេងល្បែងដ៏មានប្រយោជន៍នេះហើយ លោកគ្រូអ្នកគ្រូអាចរៀបចំជាការប្រកួតប្រជែងជាក្រុម ឬជាបុគ្គល រើសជើងឯកប្រចាំថ្នាក់ ប្រចាំសាលា... បានទៀតផង។

ស៊ូដូគុ ជាល្បែងដែលមានប្រយោជន៍សំខាន់មួយក្នុងការងារអប់រំ ពិសេសលើផ្នែកគណិតវិទ្យា។

ខាងក្រោមនេះ ជាឧទាហរណ៍សកម្មភាពសម្រាប់លោកគ្រូ អ្នកគ្រូយកទៅអនុវត្តក្នុងថ្នាក់រៀន ដើម្បីបង្កើនចំណេះដឹង និងភាពសប្បាយរីករាយ ជាពិសេសដើម្បីភាពសម្បូរបែបនៃល្បែងសិក្សា។

ក.លោកគ្រូ អ្នកគ្រូ អាចឱ្យសិស្សគូរតារាងតាមគំរូខាងក្រោមដាក់ក្នុងសៀវភៅកិច្ចការ រួចឱ្យសិស្សបំពេញលេខក្នុងប្រអប់ទាំងនោះដោយប្រើលេខពី ១ ដល់ ៤ ប៉ុន្តែត្រូវបញ្ជាក់ឱ្យបានច្បាស់ថា តាមជួរដេក តាមជួរឈរ និងក្នុងថតនីមួយៗគេមិនអាចមានលេខស្ទួនបានទេ។

ក១

| | | | |
|---|---|---|---|
| ២ | | ៤ | |
| | | | ២ |
| ១ | | | |
| | ៣ | | ១ |

| | | | |
|---|---|---|---|
| | ១ | | ២ |
| ៣ | | | |
| | | | ៤ |
| ១ | | ២ | |

| | | | |
|---|---|---|---|
| | ៣ | ៤ | |
| | | | ១ |
| ៣ | | | |
| | ២ | ១ | |

| | | | |
|---|---|---|---|
| | ៣ | ១ | |
| | | | ៣ |
| ២ | | | ៣ |
| | ៤ | ២ | |

ក២

| | | | |
|---|---|---|---|
| | ២ | ៣ | |
| | | | ៤ |
| ២ | | | |
| | ១ | ៤ | |

| | | | |
|---|---|---|---|
| | ២ | | ១ |
| | | ២ | |
| | ៣ | | |
| | ៤ | ៣ | |

| | | | |
|---|---|---|---|
| ៤ | | | ៣ |
| | | ៤ | |
| | ២ | | |
| ១ | | | ២ |

| | | | |
|---|---|---|---|
| ៤ | | | ១ |
| | ១ | | |
| | | ២ | |
| ២ | | | ៣ |

ខ.លោកគ្រូ អ្នកគ្រូ អាចប្រើប្រាស់តារាង (ថតចម្លង) ដែលត្រៀមហើយស្រេចក៏បាន។

-ចូរបំពេញលេខក្នុងប្រអប់ដោយប្រើចំនួនពី ១ ដល់ ៩។ តាមជួរឈរ ជួរដេក និងក្នុងថតនីមួយៗមិនអាចមានលេខស្ទួនបានទេ។

ខ១

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២ | | ៣ | | | ៧ | ៩ | ៤ | |
| | ៧ | | | | ៩ | | | |
| ៩ | | ៤ | ២ | | | | ៦ | |
| ៤ | ៨ | ១ | | | | | | ៦ |
| ៣ | ២ | | | | | | ៧ | ៨ |
| ៧ | | | | | | ២ | ៩ | ៤ |
| | ៤ | | | | ៥ | ៧ | | ៣ |
| | | | ១ | | | | ៥ | |
| | ៩ | ៥ | ៧ | | | ៤ | | ១ |

ខ២

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២ | | ៥ | ៣ | | ៨ | ៧ | ៤ | |
| | | | | ១ | | | | |
| | ៨ | | ៤ | | | | | ៣ |
| | ៤ | ៣ | ៦ | | | ១ | | ៧ |
| ១ | ៩ | | ៧ | | ៥ | | ៣ | ៨ |
| ៦ | | ៨ | | | ៩ | ២ | ៥ | |
| ៤ | | | | | ១ | | ៦ | |
| | | | | ៦ | | | | |
| | ១ | ៦ | ៩ | | ៤ | ៨ | | ៥ |

លោក យស់ អ៊ាខ

ស្រាវជ្រាវតាម Internet

ទំព័រស្ត្រី

# ការយល់ដឹងអំពីអនុសញ្ញាសហប្រជាជាតិ ស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (ត)

## ឃ-គោលការណ៍ស្នូលនៃអនុសញ្ញា CEDAW

ផ្អែកលើមូលដ្ឋានក្របខណ្ឌការងារ គោលការណ៍ស្នូលនៃអនុសញ្ញាមាន ៣ គឺ :

- សមភាព
- គ្មានការរើសអើង
- និងកាតព្វកិច្ចរបស់រដ្ឋ។

គោលការណ៍ខាងលើ មានលក្ខណៈពិសេសដែលមានតែនៅក្នុងអនុសញ្ញា CEDAW ទេ ដែលផ្ដល់នូវអត្ថន័យពិសេសដល់សិទ្ធិទាំងឡាយរបស់ស្ត្រី។

### ១-គោលការណ៍ទី១ : សមភាព

អនុសញ្ញា CEDAW លើកកម្ពស់គំរូសមភាពពិតប្រាកដរួមមាន :

- សមភាពនៃឱកាស
- សមភាពលទ្ធភាពទទួលបាននូវឱកាស
- សមភាពនៃលទ្ធផល។

**រូបភាពនៃផ្នែកសមភាពពិតប្រាកដ**



### ២-គោលការណ៍ទី២ : ការរើសអើង ឬការមិនរើសអើង

បន្ទាប់ពីយើងបានយល់ដឹងពីសមភាពមក ការយល់ដឹងពីគោលការណ៍ស្នូលនៃការមិនរើសអើងមានសារៈ-សំខាន់ណាស់។ យោងតាមមាត្រា១ នៃអនុសញ្ញា CEDAW : "ការរើសអើងប្រឆាំងស្ត្រីភេទ សំដៅដល់ការប្រកាន់បែងចែក ការផាត់ចេញ ឬការរឹតត្បិតផ្អែកលើភេទដែលមានអនុភាព ឬមានបំណងធ្វើឱ្យខូចខាត ឬធ្វើឱ្យមោឃៈនូវការទទួលស្គាល់ ការអាស្រ័យផល ឬការប្រើប្រាស់ដោយស្ត្រីដោយឥតគិតដល់ស្ថានភាពអាពាហ៍ពិពាហ៍របស់ស្ត្រី ផ្អែកលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រីនូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងស៊ីវិល ឬក្នុងវិស័យដទៃទៀត"។

**<u>រូបភាពនៃការរើសអើង</u>**




មានសន្ធិសញ្ញាស្តីអំពីសិទ្ធិមនុស្សជាច្រើន មិនមែនមានត្រឹមតែមួយនោះទេ ដែលហាមប្រាមការរើសអើងក្នុងនោះក៏មានរាប់បញ្ចូលទាំងអនុសញ្ញា CEDAW ផងដែរ។ សន្ធិសញ្ញាទាំងអស់នោះហាមប្រាមចំណាត់ការខុសៗគ្នាក្នុងការធានាសិទ្ធិដល់ឯកត្តជនទាំងឡាយ ក៏ប៉ុន្តែអនុសញ្ញា CEDAW ឈានឆ្ងាយទៅមុខទៀត ដើម្បីផ្តល់មូលដ្ឋានភេទដោយមានការពន្យល់ និងឱ្យនិយមន័យទូលំទូលាយនៃការរើសអើង ជាពិសេសប្រឆាំងនឹងស្ត្រី។

វិសាលភាពនៃការរើសអើងគ្របដណ្តប់ដោយអនុសញ្ញា CEDAW មិនមានកំណត់តែទៅលើវិស័យសាធារណៈនៃជីវិតនោះឡើយ។ អនុសញ្ញានេះគ្របដណ្តប់កិច្ចការនានាក្នុងវិស័យនយោបាយ វិស័យសេដ្ឋកិច្ច វិស័យសង្គម វិស័យវប្បធម៌ វិស័យស៊ីវិល និងវិស័យផ្សេងៗទៀតផង។

### ៣-គោលការណ៍ទី៣ : កាតព្វកិច្ចរដ្ឋភាគី

អនុលោមតាមអនុសញ្ញា កាតព្វកិច្ចរបស់រដ្ឋភាគីចងភ្ជាប់ជាច្បាប់ឱ្យប្រតិបត្តិតាម។

មាត្រា ២៦ នៃអនុសញ្ញា ទីក្រុងវីយែន ស្តីអំពីច្បាប់នៃសន្ធិសញ្ញា (ឆ្នាំ១៩៦៩) ចែងថា : "រាល់សន្ធិសញ្ញា

ដែលចូលជាធរមាន ចងភ្ជាប់កាតព្វកិច្ចរដ្ឋភាគីចំពោះសន្ធិសញ្ញាទាំងនោះ ហើយរដ្ឋភាគីត្រូវតែអនុវត្តសន្ធិសញ្ញាទាំងនោះដោយស្មោះត្រង់"។

មាត្រា ២៧ ចែងថា : "ក្នុងខណៈមានការខកខានមិនបានអនុវត្តសន្ធិសញ្ញា រដ្ឋភាគីមិនអាចលើកឡើងពីបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ក្នុងប្រទេសរបស់ខ្លួនមកធ្វើជាការអះអាងឱ្យខ្លួនត្រូវនោះឡើយ"។

នេះមានន័យថា រដ្ឋភាគីមានការទទួលខុសត្រូវតាមផ្លូវច្បាប់ដើម្បីប្រតិបត្តិតាមគោលការណ៍ និងមាត្រាទាំងឡាយនៃច្បាប់អន្តរជាតិដែលខ្លួនបានផ្ដល់សច្ចាប័ន។ កម្ពុជាបានចូលជាភាគីនៃអនុសញ្ញា CEDAW ក្នុងឆ្នាំ១៩៩២។ ការខកខានមិនបានបំពេញកាតព្វកិច្ចរបស់រដ្ឋភាគី គឺធ្វើឱ្យមូលដ្ឋាននៃច្បាប់សន្ធិសញ្ញាអន្តរជាតិចុះខ្សោយ។

**<u>រូបភាពនៃកាតព្វកិច្ចរបស់រដ្ឋភាគីចំពោះអនុសញ្ញា CEDAW</u>**




### តើកម្ពុជាមានកាតព្វកិច្ចអ្វីខ្លះត្រូវធ្វើក្នុងតួនាទីជារដ្ឋភាគី?

កម្ពុជាមានកាតព្វកិច្ចចាត់កិច្ចការដើម្បី "ធានា" ថា ច្បាប់ និងការប្រតិបត្តិទាំងឡាយរបស់ស្រុកទេសស្របគ្នានឹងគោលការណ៍នៃសន្ធិសញ្ញា ហើយអនុវត្តការតាក់តែងច្បាប់បន្តបន្ទាប់ដែលនៅក្នុងនោះ ការរើសអើងត្រូវបានកំណត់និយមន័យ និងហាមប្រាម ហើយទណ្ឌកម្មត្រូវបានដាក់ជាក់ហិត។ តាមរយៈនោះផងដែរ កាតព្វកិច្ចវិជ្ជមានរបស់រដ្ឋត្រូវបានកត់សម្គាល់ ព្រមជាមួយនឹងការរៀបចំស្ថាប័ននានា។

កាតព្វកិច្ចរបស់រដ្ឋភាគីរួមមានការជំរុញសមភាព និងលុបបំបាត់ការរើសអើង។ (នៅមានត)

លោកស្រី ឃួរ ស៊ីវ

ឯកសារយោង UNIFEM




# តើលោកគ្រូ អ្នកគ្រូ ដឹងទេថា...

## សើចដើម្បីសើច... និងដើម្បីព្យាបាល

សើចមិនមែនជារឿងសាមញ្ញពេកទេ ក្នុងបញ្ហាសុខភាព ពីព្រោះវាបានបង្ហាញនូវចំណុចវិជ្ជមានច្រើន ក្នុងការកែកើត និងការបង្ការរោគ ។ សើចអាចជួយសុខភាពយើងបានច្រើនយ៉ាងមានដូចជា ជួយធ្វើឱ្យល្បាយអុកស៊ីសែនក្នុងខ្លួនកាន់តែប្រសើរ ជួយបង្កើនកម្លាំងបេះដូង ជួយបន្ថយអាយតភាពសាច់ដុំ ជួយបន្ថយសម្ពាធឈាម ជួយបន្ថយភាពតានតឹងក្នុងអារម្មណ៍ ជួយបន្ធូរបន្ថយការឈឺចាប់ ជួយពង្រឹងភាពស៊ាំនឹងជំងឺផ្សេងៗ... ។ល។

គេសង្កេតឃើញថា ក្មេងៗងាយសើចណាស់ទោះជាគ្មានមូលហេតុក៏ដោយ ។ វាអាចសើចរហូតដល់បួនរយដងក្នុងមួយថ្ងៃ ។ មនុស្សចាស់សើចបានប្រហែលតែម្ដងដងនៅថ្ងៃណាដែលមានអារម្មណ៍ល្អត្រឹមត្រូវ ។

សព្វថ្ងៃនេះ នរណាក៏គេទទួលស្គាល់អំពីគុណប្រយោជន៍នៃការសើចដែរ ។ គេបានបង្កើតសមាគមអ្នកកំប្លែងធ្វើការនៅតាមមន្ទីរពេទ្យ គេបើកសិក្ខាសាលា ធ្វើកម្មសិក្សាសំណើចដោយក្រុមគ្រូពេទ្យ ផ្សព្វផ្សាយអត្ថបទ សៀវភៅសំណើច សម្ដែងរឿងកំប្លែង... នោះគឺដើម្បីជួយរួមចំណែកបម្រើសុខភាពមនុស្សជាតិ ។

បើយ៉ាងនេះទៅហើយ គួរដែរឬទេដែលយើងទ្រាំសម្ងំក្នុងភាពស្មុគស្មាញ មួម៉ៅ តប់ប្រមល់ ជ្រួញចិញ្ចើមរហូតនោះ? ត្រូវតែធ្វើជីវិតឱ្យរីករាយ ស្រស់ស្រាយ សប្បាយជានិច្ច ហើយកុំភ្លេចថា សើចកាន់តែច្រើន កាន់តែប្រសើរ ឬថាសើចច្រើនចម្រើនអាយុ ។

**លោក យស់ ស៊ាន**

# រដ្ឋជាកោះតូចៗកំពុងអភិវឌ្ឍ

## ១-នៅអាហ្វ្រិក

| ឈ្មោះប្រទេស | ប្រជាជន (ឆ្នាំ២០០៧) | ប្រវែងឆ្នេរ (គ.ម.) | ផ្ទៃដី (គ.ម.$^{២}$) |
|---|---|---|---|
| កាប់វែរ | ៤២៣ ៦១៣ | ៩៦៥ | ៤ ០៣៣ |
| កូម័រ | ៧១១ ៤១៧ | ៣៤០ | ២ ១៧០ |
| ម៉ូរីស | ១ ២៥០ ៨៨២ | ១៧៧ | ២ ០៣០ |
| សៅតូមេ និង ប្រាំងស៊ីព | ១៩៩ ៥៧៩ | ២០៩ | ១ ០០១ |
| សេយសែល | ៨១ ៨៩៥ | ៤៩១ | ៤៥៥ |

## ២-នៅអាស៊ីប៉ាស៊ីហ្វិក

| ឈ្មោះប្រទេស | ប្រជាជន (ឆ្នាំ២០០៧) | ប្រវែងឆ្នេរ (គ.ម.) | ផ្ទៃដី (គ.ម.$^{២}$) |
|---|---|---|---|
| បារ៉ែន | ៧០៨ ៥៧៣ | ១៦១ | ៦៦៥ |
| កោះឃុក | ២១ ៧៥០ | ១២០ | ២៤០ |
| ហ្វ៊ីតហ្ស៊ី | ៩១៨ ៦៧៥ | ១ ១២៩ | ១៨ ២៧០ |
| គីរីបាទី | ១០៧ ៨១៧ | ១ ១៤៣ | ៨១១ |
| ម៉ាលឌីវ | ៣៦៩ ០៣១ | ៦៤៤ | ៣០០ |
| កោះម៉ារសាល | ៦១ ៨១៥ | ៣៧០ | ១៨១ |
| មីក្រូនេស៊ី | ១០៧ ៨៦២ | ៦ ១១២ | ៧០២ |
| ណូរូ | ១៣ ៥២៨ | ៣០ | ២១ |
| នីយូអេ | ១ ៤៩២ | ៦៤ | ២៦០ |
| ប៉ាឡូវ | ២០ ៨៤២ | ១ ៥១៩ | ៤៥៨ |
| ប៉ាពូអាស៊ីហ្គីណេថ្មី | ៥ ៧៩៥ ៨៨៧ | ៥ ១៥២ | ៤៥២ ៨៦០ |
| សាម៉ូអា | ២១៤ ២៦៥ | ៤០៣ | ២ ៩៣៤ |
| សិង្ហបុរី | ៤ ៥៣៣ ០០៩ | ១៩៣ | ៦៩២ |
| កោះសាឡូម៉ុង | ៥៦៦ ៨៤២ | ៥ ៣១៣ | ២៧ ៥៤០ |
| ទីម័រខាងកើត | ១ ០៨៤ ៩៧១ | ៧០៦ | ១៥ ០០៧ |
| តូកេឡូវ | ១ ៤៤៩ | ១០១ | ១០ |
| តុងហ្គា | ១១៩ ៩២១ | ៤១៩ | ៧១៨ |

| | | | |
|---|---|---|---|
| ទូវ៉ាលូ | ១១ ៩៩២ | ២៤ | ២៦ |
| វ៉ានូអាទូ | ២១១ ៩៧១ | ២ ៥២៨ | ១២ ២០០ |

## ៣-នៅសមុទ្រការ៉ាអ៊ីប

| ឈ្មោះប្រទេស | ប្រជាជន (ឆ្នាំ២០០៧) | ប្រវែងឆ្នេរ (គ.ម.) | ផ្ទៃដី (គ.ម.$^{២}$) |
|---|---|---|---|
| អង់ទីហ្គា និង បាប៊ូដា | ៦៩ ៤៨១ | ១៥៣ | ៤៤៣ |
| អារូបា | ១០០ ០១៨ | ៦៩ | ១៩៣ |
| បាហាម៉ា | ៣០៥ ៦៥៥ | ៣ ៥៤២ | ១០ ០៧០ |
| បារបាត | ២៨០ ៩៤៦ | ៩៧ | ៤៣១ |
| គុយបា | ១១ ៣៩៤ ០៤៣ | ៣ ៧៣៥ | ១១០ ៨៦០ |
| ដូមីនីក | ៧២ ៣៨៦ | ១៤៨ | ៧៥៤ |
| សាធារណរដ្ឋដូមីនីកែន | ៩ ៣៦៥ ៨១៨ | ១ ២៨៨ | ៤៨ ៣៨០ |
| ហ្គ្រើណាត | ៨៩ ៩៧១ | ១២១ | ៣៤៤ |
| ហៃទី | ៨ ៧០៦ ៤៩៧ | ៣៦០ | ២៧ ៥៦០ |
| ហ្សាម៉ាអ៊ីក | ២ ៧៨០ ១៣២ | ១ ០២២ | ១០ ៨៣១ |
| អង់ទីយនេអៀរឡង់ដេ | ២២៣ ៦៥២ | ៣៦៤ | ៩៦០ |
| សាំងគីត និង ណេវិស | ៣៩ ៣៤៩ | ១៣៥ | ២៦១ |
| សាំងលូស៊ី | ១៧០ ៦៤៩ | ១៥៨ | ៦០៦ |
| សាំងវាំងសង់ និង ឡេក្រើណាឌីន | ១៨៨ ១៤៩ | ៨៤ | ៣៨៩ |
| ទ្រីនីតេ និងតូបាហ្គោ | ១ ០៥៦ ៦០៨ | ៣៦២ | ៥ ១២៨ |
| កោះវ្យ៉ាកអាមេរិក | ១០៨ ៤៤៨ | ១៨៨ | ៣៤៦ |

## ៤-នៅសមុទ្រមេឌីទែរ៉ាណេ

| ឈ្មោះប្រទេស | ប្រជាជន (ឆ្នាំ២០០៧) | ប្រវែងឆ្នេរ (គ.ម.) | ផ្ទៃដី (គ.ម.$^{២}$) |
|---|---|---|---|
| ស៊ីប្រ | ៧៨៨ ៤៥៧ | ៦៤៨ | ៩ ២៤០ |
| ម៉ាល់ត៍ | ៤០១ ៨៨០ | ២៥៣ | ៣១៦ |

លោក យស់ អ៊ាង

Modes de vie durables dans les îles

# ព្រះរាជាណាចក្រកម្ពុជា

## តារាងស្ថិតិសាលារៀន, ថ្នាក់រៀន, សិស្ស និង បុគ្គលិក ឆ្នាំសិក្សា២០០៧-០៨

| សេចក្តីបរិយាយលំអិត | ចំនួនសាលារៀន | សាលារៀនជួបការលំបាក | ចំនួនថ្នាក់រៀន | ចំនួនថ្នាក់រៀននៅក្នុងវត្ត | ចំនួនសិស្ស | | សិស្សរៀនត្រួតថ្នាក់ | | បុគ្គលិកបង្រៀន | | បុគ្គលិកមិនបង្រៀន | | បុគ្គលិកសរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ទូទាំងប្រទេស | 9,431 | 183 | 81,330 | 472 | 3,289,286 | 1,538,279 | 282,404 | 117,605 | 79,823 | 33,332 | 17,180 | 4,060 | 97,003 | 37,392 |
| **ទីតាំងសាលារៀន** | | | | | | | | | | | | | | |
| - តំបន់ក្រុង | 1,202 | 12 | 15,545 | 23 | 637,341 | 295,893 | 38,084 | 14,530 | 20,832 | 11,328 | 3,860 | 1,614 | 24,692 | 12,942 |
| - តំបន់ជនបទ | 7,587 | 156 | 62,403 | 424 | 2,542,227 | 1,190,732 | 228,553 | 95,795 | 56,801 | 21,435 | 13,072 | 2,405 | 69,873 | 23,840 |
| - តំបន់ដាច់ស្រយាល | 642 | 15 | 3,382 | 25 | 109,718 | 51,654 | 15,767 | 7,280 | 2,190 | 569 | 248 | 41 | 2,438 | 610 |
| **ប្រភេទសាលារៀន និង ភូមិសិក្សា** | | | | | | | | | | | | | | |
| - សាលាមត្តេយ្យសិក្សា | 1,634 | 28 | 2,678 | 30 | 79,585 | 40,013 | 0 | 0 | 2,960 | 2,914 | 170 | 159 | 3,130 | 3,073 |
| - សាលាបឋមសិក្សា | 6,476 | 148 | 60,384 | 297 | 2,311,107 | 1,094,577 | 262,191 | 111,866 | 46,921 | 20,422 | 11,855 | 2,842 | 58,776 | 23,264 |
| - អនុវិទ្យាល័យ (ថ្នាក់ទី៧-៩) | 1,006 | 7 | 7,735 | 94 | 354,479 | 166,132 | 5,124 | 1,633 | 12,577 | 4,070 | 2,399 | 405 | 14,976 | 4,475 |
| - វិទ្យាល័យ (ថ្នាក់ទី១០-១២) | 18 | 0 | 368 | 0 | 20,940 | 8,425 | 639 | 160 | 548 | 144 | 81 | 25 | 629 | 169 |
| - វិទ្យាល័យ (ថ្នាក់ទី៧-១២) | 297 | 0 | 10,165 | 51 | 523,175 | 229,132 | 14,450 | 3,946 | 16,817 | 5,782 | 2,675 | 629 | 19,492 | 6,411 |
| - មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៩) | 1,303 | 7 | 13,300 | 94 | 637,629 | 296,907 | 12,630 | 3,690 | 23,158 | 8,093 | 4,082 | 800 | 27,240 | 8,893 |
| - មធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០-១២) | 315 | 0 | 4,968 | 51 | 260,965 | 106,782 | 7,583 | 2,049 | 6,784 | 1,903 | 1,073 | 259 | 7,857 | 2,162 |
| **លក្ខណៈសាលាបឋមសិក្សា** | | | | | | | | | | | | | | |
| - កម្រង - សាលារៀនបង្គោល | 1,083 | 9 | 16,594 | 93 | 664,424 | 315,322 | 66,633 | 27,379 | 14,746 | 7,668 | 4,281 | 1,178 | 19,027 | 8,846 |
| - កម្រង - សាលារៀនសម្ព័ន្ធ | 5,393 | 139 | 43,790 | 204 | 1,646,683 | 779,255 | 195,558 | 84,487 | 32,175 | 12,754 | 7,574 | 1,664 | 39,749 | 14,418 |
| - សាលារៀនមិនស្ថិតក្នុងកម្រង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| - សាលារៀនឧបសម្ព័ន្ធ | 810 | 61 | 3,543 | 36 | 124,799 | 59,619 | 16,962 | 7,735 | 1,902 | 436 | 142 | 23 | 2,044 | 459 |
| - សាលារៀននៅក្នុងវត្ត | 1,020 | 9 | 10,100 | 0 | 386,792 | 181,880 | 42,744 | 17,652 | 8,460 | 3,637 | 2,186 | 461 | 10,646 | 4,098 |
| សាលារៀនជួបការលំបាក (គ្រប់ភូមិសិក្សា) | 183 | 183 | 861 | 2 | 28,773 | 13,550 | 3,224 | 1,450 | 557 | 196 | 79 | 18 | 636 | 214 |

## ព្រះរាជាណាចក្រកម្ពុជា

## តារាងសង្ខេបទិន្នន័យសាលារៀន សិស្ស និង បុគ្គលិក ឆ្នាំសិក្សា ២០០៧_០៨

| សេចក្តីពិពណ៌នាលំអិត | ជាមធ្យម សិស្ស/គ្រូ | ជាមធ្យម សិស្ស/បុគ្គលិក | ជាមធ្យម សិស្ស/ថ្នាក់រៀន | ជាមធ្យម សិស្ស/បន្ទប់រៀន | ជាមធ្យមថ្នាក់ រៀន/បន្ទប់រៀន | ថ្លៃបន្ទប់រៀន(ម៉ោ) សម្រាប់សិស្សម្នាក់ | ភាគរយនៃបុគ្គលិក | | %នៃគ្រូក្នុងចំណោមបុគ្គលិក | | %នៃសាលារៀនដែល | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | មិនបង្រៀន | ស្រី | បង្រៀន | មិនបង្រៀន | រៀនពីរវេន | [illegible] | គ្មានទឹក | គ្មានបង្គន់ |
| ទូទាំងប្រទេស | 41.2 | 33.9 | 40.4 | 57.8 | 1.4 | 1.0 | 17.7 | 38.5 | 41.8 | 23.6 | 61.9 | 15.4 | 39.4 | 28.3 |
| **ទីតាំងសាលារៀន** | | | | | | | | | | | | | | |
| - តំបន់ក្រុង | 30.6 | 25.8 | 41.0 | 65.0 | 1.6 | 0.9 | 15.6 | 52.4 | 54.4 | 41.8 | 57.7 | 10.6 | 36.6 | 22.7 |
| - តំបន់ជនបទ | 44.8 | 36.4 | 40.7 | 56.5 | 1.4 | 1.1 | 18.7 | 34.1 | 37.7 | 18.4 | 62.3 | 17.3 | 38.4 | 27.8 |
| - តំបន់ដាច់ស្រយាល | 50.1 | 45.0 | 32.4 | 50.9 | 1.6 | 1.1 | 10.2 | 25.0 | 26.0 | 16.5 | 65.6 | 2.3 | 56.2 | 44.5 |
| **ប្រភេទសាលារៀន និង ភូមិសិក្សា** | | | | | | | | | | | | | | |
| - សាលាមត្តេយ្យសិក្សា | 26.9 | 25.4 | 29.7 | 32.0 | 1.1 | 1.8 | 5.4 | 98.2 | 98.4 | 93.5 | 0.9 | 20.5 | 56.7 | 53.2 |
| - សាលាបឋមសិក្សា | 49.3 | 39.3 | 38.3 | 57.2 | 1.5 | 1.0 | 20.2 | 39.6 | 43.5 | 24.0 | 81.3 | 15.8 | 35.8 | 24.3 |
| - អនុវិទ្យាល័យ | 28.2 | 23.7 | 45.8 | 56.5 | 1.2 | 1.0 | 16.0 | 29.9 | 32.4 | 16.9 | 37.2 | 9.0 | 40.0 | 20.8 |
| - វិទ្យាល័យ | 31.3 | 27.0 | 51.7 | 69.9 | 1.4 | 0.9 | 13.7 | 32.7 | 34.1 | 23.7 | 59.7 | 1.6 | 21.0 | 3.5 |
| - មធ្យមសិក្សាបឋមភូមិ | 27.5 | 23.4 | 47.9 | 61.5 | 1.3 | 1.0 | 15.0 | 32.6 | 34.9 | 19.6 | 28.7 | 7.0 | 53.6 | 38.8 |
| - មធ្យមសិក្សាទុតិយភូមិ | 38.5 | 33.2 | 52.5 | 71.0 | 1.4 | 0.9 | 13.7 | 27.5 | 28.1 | 24.1 | 59.7 | 1.6 | 21.0 | 3.5 |
| **លក្ខណៈសាលាបឋមសិក្សា** | | | | | | | | | | | | | | |
| - កម្រង - សាលារៀនបង្គោល | 45.1 | 34.9 | 40.0 | 59.7 | 1.5 | 1.0 | 22.5 | 46.5 | 52.0 | 27.5 | 87.3 | 14.3 | 25.7 | 9.0 |
| - កម្រង - សាលារៀនសម្ព័ន្ធ | 51.2 | 41.4 | 37.6 | 56.3 | 1.5 | 1.1 | 19.1 | 36.3 | 39.6 | 22.0 | 80.1 | 16.0 | 37.8 | 27.4 |
| - សាលារៀនមិនស្ថិតក្នុងកម្រង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| - សាលារៀនឧបសម្ព័ន្ធ | 65.6 | 61.1 | 35.2 | 53.9 | 1.5 | 1.0 | 6.9 | 22.5 | 22.9 | 16.2 | 67.7 | 13.0 | 57.5 | 59.8 |
| - សាលារៀននៅក្នុងវត្ត | 45.7 | 36.3 | 38.3 | 54.6 | 1.4 | 1.1 | 20.5 | 38.5 | 43.0 | 21.1 | 77.5 | 100.0 | 36.2 | 19.6 |
| សាលារៀនជួបការលំបាក (គ្រប់ភូមិសិក្សា) | 51.7 | 45.2 | 33.4 | 56.5 | 1.7 | 1.0 | 12.4 | 33.6 | 35.2 | 22.8 | 61.2 | 6.6 | 100.0 | 100.0 |

*ការិយាល័យស្ថិតិ, នាយកដ្ឋានផែនការ* — *ក្រសួងអប់រំ យុវជន និង កីឡា*

# ព្រះរាជាណាចក្រកម្ពុជា

## តារាងអាំងឌីកាទ័រចូលរៀន និង សមធម៌ ឆ្នាំសិក្សា២០០៧-០៨

| សេចក្តីបរិយាយ | អត្រាពិតចូលរៀនថ្មី នៅបឋមសិក្សា | | | អត្រាពិតនៃការសិក្សា នៅបឋមសិក្សា | | | អត្រាពិតនៃការសិក្សា មធ្យមសិក្សាបឋមភូមិ | | | អត្រាពិតនៃការសិក្សា មធ្យមសិក្សាទុតិយភូមិ | | | អត្រាឆ្លងភូមិសិក្សាចូល មធ្យមសិក្សាបឋមភូមិ | | | អត្រាឆ្លងភូមិសិក្សាចូល មធ្យមសិក្សាទុតិយភូមិ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស | សរុប | ស្រី | ប្រុស |
| **ទូទាំងប្រទេស** | 89.5 | 89.7 | 89.3 | 93.3 | 93.3 | 93.2 | 34.8 | 35.9 | 33.7 | 14.8 | 13.8 | 15.7 | 78.9 | 78.5 | 79.3 | 71.5 | 71.0 | 71.8 |
| **តំបន់ក្រុង** | 92.6 | 93.1 | 92.1 | 92.7 | 93.1 | 92.4 | 55.9 | 56.9 | 55.0 | 41.3 | 40.2 | 42.4 | 93.5 | 93.5 | 93.5 | 94.6 | 94.8 | 94.4 |
| **តំបន់ជនបទ** | 89.3 | 89.4 | 89.1 | 93.6 | 93.6 | 93.6 | 31.5 | 32.6 | 30.4 | 10.0 | 8.9 | 11.0 | 76.1 | 75.7 | 76.4 | 62.2 | 60.8 | 63.2 |
| **តំបន់ដាច់ស្រយាល** | 82.6 | 82.1 | 83.0 | 88.4 | 87.8 | 89.0 | 11.1 | 12.2 | 10.1 | 1.2 | 1.2 | 1.1 | 68.7 | 67.6 | 69.8 | 39.3 | 36.2 | 41.5 |
| បន្ទាយមានជ័យ | 92.9 | 92.3 | 93.5 | 95.2 | 94.7 | 95.6 | 32.3 | 34.9 | 30.0 | 11.4 | 11.8 | 10.9 | 73.7 | 74.5 | 73.0 | 70.6 | 71.5 | 69.9 |
| បាត់ដំបង | 87.7 | 88.3 | 87.2 | 87.5 | 91.5 | 84.1 | 27.8 | 30.3 | 25.4 | 10.2 | 10.1 | 10.3 | 74.7 | 76.4 | 73.1 | 71.0 | 69.2 | 72.6 |
| កំពង់ចាម | 91.4 | 91.3 | 91.4 | 94.0 | 94.6 | 93.5 | 25.7 | 26.8 | 24.6 | 9.3 | 9.2 | 9.3 | 74.0 | 74.1 | 74.0 | 66.8 | 68.0 | 65.9 |
| កំពង់ឆ្នាំង | 88.8 | 90.9 | 86.9 | 97.2 | 96.9 | 97.4 | 38.4 | 40.7 | 36.3 | 12.8 | 12.5 | 13.1 | 74.1 | 73.9 | 74.2 | 66.9 | 67.9 | 66.2 |
| កំពង់ស្ពឺ | 88.2 | 89.7 | 86.8 | 93.2 | 92.2 | 94.2 | 27.6 | 27.3 | 27.9 | 7.6 | 5.8 | 9.5 | 78.2 | 76.3 | 80.0 | 63.0 | 62.2 | 63.4 |
| កំពង់ធំ | 88.9 | 87.5 | 90.4 | 93.8 | 93.3 | 94.4 | 26.6 | 29.5 | 23.8 | 11.5 | 11.1 | 12.0 | 79.7 | 80.9 | 78.5 | 74.6 | 71.8 | 76.7 |
| កំពត | 88.3 | 87.7 | 88.8 | 92.7 | 92.6 | 92.8 | 44.8 | 44.4 | 45.3 | 21.3 | 18.9 | 23.7 | 80.4 | 80.5 | 80.3 | 69.5 | 67.2 | 71.3 |
| កណ្តាល | 92.8 | 92.3 | 93.3 | 98.2 | 98.2 | 98.2 | 46.3 | 49.5 | 43.4 | 17.7 | 16.6 | 18.8 | 82.3 | 81.6 | 82.9 | 70.1 | 70.5 | 69.7 |
| កែប | 88.3 | 86.2 | 90.7 | 96.4 | 95.3 | 97.4 | 35.5 | 39.2 | 32.0 | 16.3 | 16.2 | 16.4 | 83.8 | 85.6 | 82.1 | 79.9 | 75.3 | 83.8 |
| កោះកុង | 82.0 | 85.5 | 78.8 | 81.6 | 81.8 | 81.5 | 22.3 | 23.6 | 21.1 | 7.6 | 7.4 | 7.8 | 73.1 | 72.5 | 73.6 | 73.6 | 69.8 | 76.2 |
| ក្រចេះ | 88.9 | 87.2 | 90.6 | 96.7 | 96.4 | 97.0 | 31.3 | 32.9 | 29.8 | 13.5 | 13.1 | 14.1 | 80.8 | 81.2 | 80.3 | 70.4 | 67.4 | 72.9 |
| មណ្ឌលគិរី | 88.5 | 85.6 | 91.3 | 90.0 | 90.3 | 89.8 | 11.4 | 13.4 | 9.7 | 4.6 | 5.5 | 3.8 | 96.1 | 98.4 | 94.5 | 88.1 | 89.0 | 87.6 |
| ឧត្តរមានជ័យ | 93.0 | 92.7 | 93.3 | 96.6 | 96.8 | 96.4 | 19.1 | 20.8 | 17.6 | 3.1 | 2.8 | 3.4 | 71.7 | 73.1 | 70.4 | 66.9 | 62.0 | 69.9 |
